អង្គការសហប្រជាជាតិ

A/HRC/57/17

# មហាសន្និបាត

ផ្សព្វផ្សាយ ៖ ទូទៅ
ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤

ច្បាប់ដើម៖ ភាសាអង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**សម័យប្រជុំលើកទីហាសិបប្រាំពីរ**
ថ្ងៃទី៩ ខែកញ្ញា–ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៤
របៀបវារៈទី ៦
**ការពិនិត្យឡើងវិញជាសកលតាមកាលកំណត់**

# របាយការណ៍របស់ក្រុមការងារស្តីពី ការពិនិត្យឡើងវិញជាសកលតាមកាលកំណត់*

# កម្ពុជា

* ឧបសម្ព័ន្ធនឹងត្រូវបានចែកចាយដោយពុំមានការកែសម្រួលជាផ្លូវការ ជាភាសាដើមនៃអត្ថបទតែប៉ុណ្ណោះ។

# សេចក្តីផ្តើម

១.	ក្រុមការងារស្តីពីការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ ត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមសេចក្តីសម្រេច ៥/១ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលក្រុមការងារនេះ បានរៀបចំសម័យប្រជុំលើកទីសែសិបប្រាំមួយរបស់ខ្លួនចាប់ពីថ្ងៃទី២៩ ខែមេសា ដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤។ ការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ របស់កម្ពុជាត្រូវបានរៀបចំឡើងក្នុងសម័យប្រជុំទី១៥ នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៤។ គណៈប្រតិភូប្រទេសកម្ពុជា ក្រោមការដឹកនាំរបស់ ឯកឧត្តម កែវ សុទ្ធិ ដែលជាអនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។ នៅសម័យប្រជុំទី១៧ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ ក្រុមការងារនេះ បានអនុម័តរបាយការណ៍ស្តីពីការពិនិត្យជាសកលតាមកាលកំណត់របស់កម្ពុជា។

២.	នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានជ្រើសរើសក្រុមអ្នករាយការណ៍ (រដ្ឋសមាជិកចំនួន៣) ដើម្បីសម្របសម្រួលការពិនិត្យឡើងវិញរបស់កម្ពុជា ៖ ប្រទេសហ្គាណា ជប៉ុន និង ម៉ុងតេណេក្រូ។

៣.	ដោយអនុលោមទៅតាមកថាខណ្ឌ ១៥ នៃឧបសម្ព័ន្ធក្នុងសេចក្តីសម្រេច ៥/១ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងកថាខណ្ឌ ៥ នៃឧបសម្ព័ន្ធក្នុងសេចក្តីសម្រេច ១៦/២១ របស់ក្រុមប្រឹក្សានេះ ឯកសារខាងក្រោមនេះត្រូវបានរៀបចំឡើងសម្រាប់ការពិនិត្យឡើងវិញរបស់កម្ពុជា៖

(ក)	របាយការណ៍ជាតិ ដែលបានដាក់ជូន/បទបង្ហាញជាលាយលក្ខណ៍អក្សរ ដែលត្រូវបានរៀបចំដោយអនុលោមទៅតាមកថាខណ្ឌ ១៥ (ក)[1]

(ខ)	ការចងក្រងឯកសារ របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដោយអនុលោមទៅតាមកថាខណ្ឌ ១៥ (ខ)[2]

(គ)	សេចក្តីសង្ខេប ដែលរៀបចំដោយ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដោយអនុលោមទៅតាមកថាខណ្ឌ ១៥ (គ)[3]។

៤.	បញ្ជីសំណួរដែលត្រូវបានរៀបចំជាមុនដោយ ប្រទេសប៊ែលហ្សិក អាល្លឺម៉ង់ លិចតិនស្តាញ ព្រះរាជាណាចក្រហូឡង់ ព័រទុយហ្គាល់ ជំនួសមុខឱ្យក្រុមសម្ព័ន្ធមិត្ត ស្តីពីយន្តការជាតិ នៃការអនុវត្ត ការរាយការណ៍ និងការតាមដានបន្ត ប្រទេសស្លូវេនី ស៊ុយអែត ចក្រភពអង់គ្លេស និងប្រទេសអៀរឡង់ខាងជើង និងសហរដ្ឋអាមេរិក ត្រូវបានបញ្ជូនទៅកម្ពុជា តាមរយៈរដ្ឋសមាជិកទាំងបីដែលជាអ្នករាយការណ៍។ សំណួរទាំងនេះមានលើគេហទំព័រនៃការពិនិត្យឡើងវិញជាសកលតាមកាលកំណត់។

[1] A/HRC/WG.6/46/KHM/1.
[2] A/HRC/WG.6/46/KHM/2.
[3] A/HRC/WG.6/46/KHM/3.

# I. សេចក្តីសង្ខេបនៃនីតិវិធីដំណើរការពិនិត្យឡើងវិញ

## ក. បទបង្ហាញដោយរដ្ឋដែលស្ថិតក្រោមការពិនិត្យឡើងវិញ

៥. គណៈប្រតិភូកម្ពុជាបានថ្លែងថា កម្ពុជាបានបង្កើតកិច្ចសហប្រតិបត្តិការជិតស្និទ្ធ និងបែបស្ថាបនាជាមួយយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ ការចូលរួមរបស់កម្ពុជានៅក្នុងវដ្ត UPR ទាំងបីលើកកន្លងមក រួមចំណែកក្នុងដំណើរការពង្រឹងប្រព័ន្ធកិច្ចការពារសិទ្ធិមនុស្សថ្នាក់ជាតិដែលមានស្រាប់ ការពង្រីកលំហពលរដ្ឋ និងនយោបាយ និងការពង្រឹងសិទ្ធិសេដ្ឋកិច្ចសង្គម។ លទ្ធផលគួរឱ្យកត់សម្គាល់ ដែលជាលទ្ធផលនៃអនុសាសន៍ដែលបានទទួលយកពីវដ្តមុនៗ រួមមាន ការរៀបចំបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស។

៦. តម្លៃប្រជាធិបតេយ្យ និងសិទ្ធិមនុស្សមានលក្ខណៈជាក់លាក់ស្របតាមបរិបទប្រទេស ហើយកម្ពុជាបានអនុវត្តតម្លៃទាំងនោះដោយពិចារណា ប្រវត្តិសាស្ត្រ វប្បធម៌ និងដំណាក់កាលនៃការអភិវឌ្ឍរបស់ខ្លួន ដើម្បីធានានូវការសម្រេចបានជាក់ស្តែង។

៧. ដោយសារកម្ពុជាបានបន្តអភិវឌ្ឍមិនឈប់ឈរ ប្រជាជនកម្ពុជារាប់លាននាក់បាន ចាកផុតពីភាពក្រីក្រទាំងស្រុង និងកំពុងរីករាយនឹងជីវភាពរស់នៅសមរម្យ ដោយអាយុកាលមធ្យមកើនឡើងគួរឱ្យកត់សម្គាល់ តាមរយៈគោលនយោបាយឈ្នះឈ្នះរបស់អតីតនាយករដ្ឋមន្ត្រី។ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ ចាត់អាទិភាពចំពោះការអភិវឌ្ឍមូលធនមនុស្ស តាមរយៈការពង្រីកកិច្ចគាំពារ និងជំនួយសង្គម ការគាំទ្រការឆ្លើយតបគ្រោះអាសន្ន និងការពង្រឹងសុខុមាលភាពគ្រប់ជ្រុងជ្រោយ។

៨. សេដ្ឋកិច្ចរបស់កម្ពុជាស្ថិតក្នុងចំណោមសេដ្ឋកិច្ចដែលរីកចម្រើនលឿនបំផុត និងគ្រោងក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលកម្រិតខ្ពស់ នៅឆ្នាំ២០៥០។ ការសម្រេចបានគោលដៅភាគច្រើន នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំង ១៧ កំពុងមានវឌ្ឍនភាពទៅមុខជាបន្តបន្ទាប់។

៩. កម្ពុជាបានអនុវត្តកម្មវិធីជំនួយសង្គមនានាជាច្រើន។ ប្រព័ន្ធសន្តិសុខសង្គមដែលកាន់តែប្រសើរ ត្រូវបានបញ្ចូលក្នុងកញ្ចប់គ្រួសារ។ កម្ពុជាបានរៀបចំផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា សម្រាប់ឆ្នាំ ២០២៤-២០៣៥។ ប្រព័ន្ធកិច្ចគាំពារសង្គមបានផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋសរុបចំនួន ៤២,១% នៅឆ្នាំ២០២៤។

១០. កម្ពុជាបានទទួលស្គាល់ឥទ្ធិពលនៃបរិវត្តកម្មបច្ចេកវិទ្យាឌីជីថល សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ ប្រទេសនេះកំពុងពង្រីកការតភ្ជាប់សេវាអ៊ីនធឺណិតដែលនឹងអនុញ្ញាតឱ្យឃុំសង្កាត់ទាំងអស់អាចប្រើប្រព័ន្ធអ៊ីនធឺណិតបាន ត្រឹមឆ្នាំ២០២៧។ រដ្ឋាភិបាល កំពុងធ្វើបរិវត្តកម្មខ្លួនឱ្យក្លាយទៅជារដ្ឋាភិបាលឌីជីថល។ រដ្ឋាភិបាលបានរៀបចំ

សេចក្ដីព្រាងច្បាប់គ្រប់ជ្រុងជ្រោយមួយស្ដីពី កិច្ចការពារទិន្នន័យផ្ទាល់ខ្លួន ដែលនឹងជួយរក្សាសិទ្ធិរបស់ប្រជាជនរបស់ខ្លួនក្នុងការទទួលបានឯកជនភាព និងការការពារទិន្នន័យ។

១១. រដ្ឋធម្មនុញ្ញកម្ពុជាចែងយ៉ាងច្បាស់ អំពីធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងលិខិតុបករណ៍សិទ្ធិមនុស្សនានា។ កម្ពុជាបានសហការយ៉ាងមោះមុតជាមួយនឹងស្ថាប័នសន្ធិសញ្ញាអង្គការសហប្រជាជាតិ និងដៃគូពាក់ព័ន្ធ។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាបានសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធ ដើម្បីចងក្រងរបាយការណ៍សម្រាប់ដាក់ជូនស្ថាប័នសន្ធិសញ្ញានីមួយៗ និងការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ ព្រមទាំងតាមដានការអនុវត្តអនុសាសន៍នានា តាមរយៈក្រុមការងារអន្តរក្រសួង។

១២. OHCHR និងវេទិកាអាស៊ីប៉ាស៊ីហ្វិកនៃស្ថាប័នជាតិសិទ្ធិមនុស្ស បានចូលរួមផ្ដល់ការគាំទ្រដល់ការបញ្ចប់សេចក្ដីព្រាងច្បាប់ ស្ដីពីការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស។ មានការរៀបចំកិច្ចពិគ្រោះយោបល់មួយចំនួនទាក់ទងនឹងសេចក្ដីព្រាងច្បាប់នេះ ដើម្បីធានាថាច្បាប់នេះអនុលោមទៅតាមគោលការណ៍ទីក្រុងប៉ារីស។ សេចក្ដីព្រាងច្បាប់នេះត្រូវបានដាក់ជូនគណៈរដ្ឋមន្ត្រីនៅចុងឆ្នាំ ២០២៣ ហើយកំពុងរង់ចាំការកែសម្រួលបន្ថែមពីសំណាក់ក្រុមប្រឹក្សាអ្នកច្បាប់។

១៣. កម្ពុជានៅតែប្ដេជ្ញាចិត្តចំពោះការអប់រំ និងការរៀនសូត្រពេញមួយជីវិត ប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ សម្រាប់មនុស្សគ្រប់រូប។ សិទ្ធិទទួលបានការអប់រំមានចែងក្នុងរដ្ឋធម្មនុញ្ញ ដែលធានាការទទួលបានការអប់រំដោយឥតគិតថ្លៃយ៉ាងហោចណាស់ត្រឹមថ្នាក់ទី៩។ ក្នុងការអនុវត្តជាក់ស្ដែង ការអប់រំនៅកម្ពុជាគឺផ្ដល់ដោយឥតគិតថ្លៃចាប់ពីថ្នាក់មត្តេយ្យសិក្សា រហូតដល់ថ្នាក់វិទ្យាល័យ (ថ្នាក់មត្តេយ្យដល់ថ្នាក់ទី១២)។

១៤. អាទិភាពរបស់ក្រសួងអប់រំ រួមមានអភិបាលកិច្ចសាលារៀន កម្មវិធីសិក្សា និងសកម្មភាពសិក្សាបន្ថែមក្រៅកម្មវិធីសិក្សា អាហារូបត្ថម្ភសម្រាប់កុមារ និងគុណភាពអាហារក្នុងសាលារៀន ភាពជាដៃគូរវាងរដ្ឋ និងសហគមន៍ ការចូលរួមរបស់ឪពុកម្ដាយ និងអាណាព្យាបាល ការអប់រំបែបឌីជីថល មជ្ឈមណ្ឌលឧត្ដមភាពក្នុងការអប់រំកម្រិតឧត្ដមសិក្សា ការអភិវឌ្ឍសមត្ថភាព ព្រមទាំងការអភិវឌ្ឍរូបវន្ត និងកីឡា។ ក្រសួងអប់រំបានអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ សម្រាប់ការអប់រំថ្នាក់មធ្យមសិក្សា ដែលអនុលោមនឹងកម្មវិធីវាយតម្លៃសិស្សកម្រិតអន្តរជាតិ និងបានលើកកម្ពស់ថ្នាលអប់រំឌីជីថល និងវេទិការៀនតាមប្រព័ន្ធអេឡិចត្រូនិច និងពង្រឹងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ។

១៥. ចាប់ពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០២៣ ក្រសួងអប់រំបានសាងសង់អគារសាលារៀនថ្មីចំនួន ៥០៣ខ្នង និងបានជួសជុលអគារសាលារៀនចំនួន ៤៣៨ខ្នង ដោយកញ្ចប់ថវិការបស់ក្រសួង និងការគាំទ្រពីធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី សហភាពអឺរ៉ុប និងប្រទេសចិន ទន្ទឹមនឹងនោះរដ្ឋាភិបាលបានសាងសង់អគារសាលារៀនចំនួន ៤.៥៤៥ ខ្នង។ ក្រសួងនេះក៏បានរៀបចំយុទ្ធនាការសាលារៀនស្អាតផងដែរ។

១៦. ក្រសួងអប់រំបានផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូឧទ្ទេស អំពីការទប់ស្កាត់ការកេងប្រវ័ញ្ចកុមារតាមប្រព័ន្ធអនឡាញ ការរំលោភបំពានផ្លូវភេទ និងជំងឺកាមរោគ។ រដ្ឋាភិបាលបានបញ្ចូលនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ទៅក្នុងកម្មវិធីសិក្សាសម្រាប់សិស្សានុសិស្ស ស្របតាមកម្រិតអាយុ ដើម្បីប្រយុទ្ធប្រឆាំងនឹងការរើសអើង។ សិទ្ធិទទួលបានការអប់រំរបស់អ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់ទី៥ ដល់ថ្នាក់ទី១២។ កម្ពុជាក៏ផ្តោតការយកចិត្តទុកដាក់លើការទទួលបានការអប់រំប្រកបដោយសមធម៌ និងបរិយាបន្នដែរ។ កុមារមានពិការភាព ពីក្រុមភាគតិច កុមារជនជាតិដើមភាគតិច និងកុមាររស់នៅក្នុងតំបន់ប្រឈមនៅទីជនបទ និងទីក្រុង ត្រូវបានកំណត់ថាជាក្រុមអាទិភាព។

## ខ. កិច្ចសន្ទនាអន្តរកម្ម និងឆ្លើយតបរបស់រដ្ឋដែលស្ថិតក្រោមការពិនិត្យឡើងវិញ

១៧. ក្នុងអំឡុងកិច្ចសន្ទនាអន្តរកម្ម គណៈប្រតិភូចំនួន ១០០នាក់ បានធ្វើសេចក្តីថ្លែងការណ៍។ អនុសាសន៍ ដែលត្រូវបានផ្តល់ក្នុងអំឡុងកិច្ចសន្ទនា មានក្នុងផ្នែកទីពីរ នៃរបាយការណ៍នេះ។

១៨. សាធារណរដ្ឋឥស្លាមអ៊ីរ៉ង់ ទទួលស្គាល់កំណើនសេដ្ឋកិច្ចជាច្រើនទសវត្សរ៍ជាលទ្ធផលធ្វើឱ្យមានការកាត់បន្ថយភាពក្រីក្រគួរឱ្យកត់សម្គាល់។

១៩. អ៊ីរ៉ាក់ សាទរចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងវិស័យកំណែទម្រង់អភិបាលកិច្ច និងការកើនឡើងនៃកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

២០. អៀរឡង់ សោកស្តាយចំពោះការរួមតូចនៃលំហសង្គមស៊ីវិល និងការចោទប្រកាន់ថាមានអំពើទារុណកម្ម និងការប្រព្រឹត្តមិនគប្បីចំពោះអ្នកជាប់ឃុំឃាំង ។

២១. អ៊ីតាលី សាទរចំពោះកិច្ចសហប្រតិបត្តិការរបស់កម្ពុជា ជាមួយយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ជាពិសេស ជាមួយនឹង OHCHR។

២២. ជប៉ុន សាទរចំពោះការបន្ត MOU ជាមួយនឹងការិយាល័យប្រចាំប្រទេសរបស់ OHCHR និងទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

២៣. កៀហ្ស៊ីស្ថានផ្តល់អនុសាសន៍មួយចំនួន។

២៤. សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ កោតសរសើរចំពោះសមិទ្ធផលក្នុងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍជនបទ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ។

២៥. លីបង់ ស្វាគមន៍ការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការពង្រឹងវិស័យអប់រំ និងការថែទាំសុខភាព ព្រមទាំងកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងការរើសអើងគ្រប់ទម្រង់។

២៦. ឡេសូតូ សាទរចំពោះវឌ្ឍនភាពគួរឱ្យសរសើរក្នុងការបង្កើនកម្រិតជីវភាពរស់នៅ ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្រ។

២៧. លិចតិនស្តាញ ផ្តល់អនុសាសន៍មួយចំនួន។

២៨. លីទុយអានី ទទួលស្គាល់វឌ្ឍនភាពក្នុងការលើកកម្ពស់ និងការការពារសិទ្ធិរបស់ជនមានពិការភាព និងកត់សម្គាល់អំពីកំណែទម្រង់លើការទទួលបានការអប់រំ និងការថែទាំសុខភាព។

២៩. លុចសំបួ ផ្តល់អនុសាសន៍មួយចំនួន។

៣០. ម៉ាឡាវី ផ្តល់អនុសាសន៍មួយចំនួន។

៣១. ម៉ាឡេស៊ី អបអរសាទរចំពោះកិច្ចខិតខំប្រឹងប្រែងមួយចំនួន ដើម្បីពង្រឹងវិស័យសុខាភិបាល អប់រំ ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្រ។

៣២. ម៉ាល់ឌីវ កោតសរសើរចំពោះការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការធានានូវសកលកម្ម និងសមធម៌ទឹកបរិភោគដែលមានសុវត្ថិភាព និងថ្លៃសមរម្យសម្រាប់ប្រជាជនទាំងអស់។

៣៣. ម៉ាល់តា នៅតែព្រួយបារម្ភចំពោះការបង្ក្រាបប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ អង្គការសង្គមស៊ីវិល និងបក្សនយោបាយប្រឆាំង។

៣៤. ម៉ូរីស កោតសរសើរកម្ពុជាចំពោះការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលបានកាត់បន្ថយកម្រិតភាពក្រីក្រស្ទើរតែពាក់កណ្តាលចាប់តាំងពីឆ្នាំ ២០០៩។

៣៥. ម៉ិចស៊ិក ស្វាគមន៍ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ក្នុងចំណោមវិធានការផ្សេងទៀត។

៣៦. ម៉ុងហ្គោលី ផ្តល់អនុសាសន៍មួយចំនួន។

៣៧. ម៉ុងតេណេហ្គ្រោ ជំរុញឱ្យបង្កើនវឌ្ឍនភាពបន្ថែមទៀតលើកិច្ចការពារស្ត្រី និងកុមារ។

៣៨. ម៉ារ៉ុក កោតសរសើរកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងសិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

៣៩. នេប៉ាល់ សាទរវិធានការនានា ដែលត្រូវបានអនុវត្ត ដើម្បីពង្រឹងតួនាទីរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច និងការដោះស្រាយបញ្ហាពលកម្មកុមារ។

៤០. ព្រះរាជាណាចក្រហូឡង់ បង្ហាញការព្រួយបារម្ភ អំពីការសងសឹកក្រៅផ្លូវច្បាប់ និងការរឹតបន្តឹងតាមទំនើងចិត្តលើអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងអង្គការសង្គមស៊ីវិល។

៤១. នូវែលសេឡង់ ស្វាគមន៍ចេតនារបស់កម្ពុជា ក្នុងការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ដែលអនុលោមតាមគោលការណ៍ទីក្រុងប៉ារីស។

៤២. នីវេស កត់សម្គាល់ថានៅតែព្រួយបារម្ភអំពីការអភិវឌ្ឍប្រជាធិបតេយ្យ និងលំហនយោបាយ និងពលរដ្ឋ ដែលមានការរឹតត្បិត។

៤៣. ប៉ាគីស្ថាន សាទរចំពោះកម្មវិធីនានា ដែលកម្ពុជាអនុវត្តដើម្បីអភិវឌ្ឍសេដ្ឋកិច្ចសង្គម ការកាត់បន្ថយភាពក្រីក្រ ការផ្គត់ផ្គង់ទឹកស្អាត និងការពង្រឹងលទ្ធភាពទទួលបានការថែទាំសុខភាព។

៤៤. ប៉ាណាម៉ា ផ្តល់អនុសាសន៍មួយចំនួន។

៤៥. ប៉ារ៉ាហ្គាយ ជំរុញបន្ថែមទៀត ចំពោះការពង្រឹងក្របខណ្ឌលិខិតបទដ្ឋានគតិយុត្ត ស្ថាប័ន និងគោលនយោបាយ ផ្តោតលើអភិក្រមសិទ្ធិមនុស្ស។

៤៦. ហ្វីលីពីន កត់សម្គាល់ចំពោះការធ្លាក់ចុះនៃអត្រាមរណភាពមាតា ទារក និងកុមារអាយុក្រោម ៥ឆ្នាំ ព្រមទាំងការពង្រីកហេដ្ឋារចនាសម្ព័ន្ធសាលារៀន។

៤៧. កម្ពុជាថ្លែងថា ត្រឹមខែមេសា ឆ្នាំ២០២៤ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានចេញបណ្ណកម្មសិទ្ធិដីចំនួន ៧.៤៩៥.៩៥១បណ្ណ និងបង្កើតស្ថានីយវាស់វែងដីជាអចិន្ត្រៃយ៍ចំនួន ៦៥ស្ថានីយ នៅតាមរាជធានី-ខេត្តទូទាំងប្រទេស។ ក្រសួងនេះបានដោះស្រាយករណីវិវាទដីធ្លីសរុបចំនួន ១៥.០៦១ករណី និងកំពុងដោះស្រាយចំនួន ១.៧៧១ ករណី។

៤៨. កម្ពុជាបានអនុម័តគោលនយោបាយស្តីពីការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច ដោយចេញបណ្ណកម្មសិទ្ធិដីសមូហភាពចំនួន ៤២ សហគមន៍ និងសម្របសម្រួលការស្នើសុំការចុះបញ្ជីដីសមូហភាព។

៤៩. កម្ពុជាបានដាក់ចេញនូវគោលការណ៍ និងវិធានការនានា ដើម្បីសម្រេចបានសមភាពយេនឌ័រ និងដើម្បីទទួលបានផលប្រយោជន៍ប្រកបដោយសមធម៌រវាងស្ត្រី និងបុរសនៅក្នុងវិស័យដីធ្លី។

៥០. កម្ពុជាបានផ្តល់អាទិភាពចំពោះការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងគ្រប់វិស័យ តាមរយៈរបៀបវារៈគោលនយោបាយ និងយុទ្ធសាស្ត្របញ្ជាកោណរបស់ខ្លួន។ កម្ពុជាលើកកម្ពស់សមភាពយេនឌ័រតាម រយៈការបង្កើនការវិនិយោគលើស្ត្រីក្នុងវិស័យសេដ្ឋកិច្ច អប់រំ សុខាភិបាល ភាពជាអ្នកដឹកនាំសាធារណៈ និងអភិបាលកិច្ច។ ភាពជាតំណាងរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត ក្នុងវិស័យសាធារណៈមានភាពកើនឡើងនៅគ្រប់កម្រិត។

៥១. មានសមភាពយេនឌ័រក្នុងវិស័យអប់រំ ជាពិសេស ក្នុងការអប់រំកម្រិតថ្នាក់បឋមសិក្សា និងមធ្យមសិក្សា។ កម្ពុជាកំពុងរៀបចំផែនការសកម្មភាពជាតិបន្ទាប់ស្តីពីការទប់

ស្កាត់អំពើហិង្សាលើស្ត្រី។ អំពើហិង្សាពីដៃគូស្និទ្ធស្នាលបានធ្លាក់ចុះ។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ គ្រោងនឹងត្រូវបានពិនិត្យឡើងវិញ ដើម្បីធានាថាច្បាប់នេះអនុលោមតាមបទដ្ឋានអន្តរជាតិ។ បណ្តាញទូរស័ព្ទទាន់ហេតុការណ៍ចំនួនពីរខ្សែត្រូវបានដាក់ឱ្យប្រើប្រាស់ ព្រមជាមួយបទដ្ឋាននីតិវិធីប្រតិបត្តិ ដើម្បីផ្តល់ព័ត៌មាន និងការបញ្ជូនជនរងគ្រោះនៃអំពើហិង្សាយេនឌ័រ។

៥២. ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់នៅតែជាអាទិភាព។ កម្ពុជាបានធ្វើការសិក្សាថ្នាក់ជាតិមួយ ហើយនឹងប្រើប្រាស់លទ្ធផលនៃការសិក្សានេះ ដើម្បីរៀបចំផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សា និងអាពាហ៍ពិពាហ៍វ័យកុមារ។

៥៣. កម្ពុជាជាប្រទេសទីមួយ ដែលអនុវត្តកម្មវិធីរោងចក្រកាន់តែប្រសើរ នៅកម្ពុជារបស់អង្គការ ILO និងជាប្រទេសមួយក្នុងចំណោមប្រទេសមួយចំនួនតូច ដែលអនុវត្តកម្មវិធីការងារសមរម្យប្រចាំប្រទេស របស់អង្គការ ILO។ រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសហជីព អនុលោមពេញលេញតាមអនុសញ្ញាលេខ ៨៧ របស់អង្គការ ILO ដោយកម្មករ និងនិយោជកមានសិទ្ធិក្នុងការបង្កើតអង្គការវិជ្ជាជីវៈរៀងៗខ្លួន និងប្រើប្រាស់សេរីភាពរបស់ពួកគេ ដោយគ្មានការបំភិតបំភ័យ។

៥៤. ច្បាប់ស្តីពីសហជីព ត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ ២០២០ បន្ទាប់ពីមានកិច្ចចរចាត្រីភាគីជាច្រើនលើកច្រើនសារ និងការគាំទ្របច្ចេកទេសពី ILO។ នៅត្រឹមខែមីនា ឆ្នាំ២០២៤ កម្ពុជាមានអង្គការវិជ្ជាជីវៈចំនួន ៦.៣១៧អង្គការ ដែលស្មើនឹងកំណើនចំនួន ៧៤,២១% ធៀបនឹងអង្គការដែលបានចុះបញ្ជីនៅមុនការអនុម័តច្បាប់ស្តីពីសហជីពនៅឆ្នាំ២០១៦។ មិនដែលមានការបដិសេធចំពោះពាក្យសុំចុះបញ្ជីឡើយ។ ពុំដែលមានការចាប់ខ្លួន ឬផ្តន្ទាទោសតាមវិធានការច្បាប់ចំពោះ តំណាងសហជីព នោះឡើយ។

៥៥. កម្ពុជាមានកម្លាំងការងារវ័យក្មេងជាច្រើន។ សហគ្រាសនានា ដែលមានបំណងជួលយុវជនអាយុរវាង ១៥ឆ្នាំ និង១៧ឆ្នាំ តម្រូវឱ្យស្វែងរកការអនុញ្ញាតជាមុនពីមន្ត្រីអធិការកិច្ចការងារ ហើយការមិនអនុលោមតាមតម្រូវការនេះ នឹងត្រូវរងពិន័យធ្ងន់ធ្ងរ។ កម្ពុជាគោរពពេញលេញតាមអនុសញ្ញាលេខ ១៣៨ របស់អង្គការ ILO។ លិខិតបទដ្ឋានគតិយុត្តថ្មីកំពុងត្រូវបានធ្វើសេចក្តីព្រាង ដើម្បីបង្កើនអាយុអប្បបរមាដែលអាចធ្វើការក្នុងវិស័យរោងចក្រ ទៅអាយុ ១៦ឆ្នាំ និងទៅអាយុ ១៨ឆ្នាំ សម្រាប់វិស័យនាំចេញ។

៥៦. កិច្ចប្រជុំជាសាធារណៈជាប្រចាំរវាងនាយករដ្ឋមន្ត្រី និងកម្មករត្រូវបានរៀបចំឡើង ដែលជាលទ្ធផលមានអនុសាសន៍មួយចំនួន ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវអនុវត្ត។

៥៧. ប្រាក់ឈ្នួលអប្បបរមាត្រូវបានបង្កើនជារៀងរាល់ឆ្នាំ ស្របតាមអនុសញ្ញាស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមា ឆ្នាំ១៩២៨ (លេខ ២៦) របស់អង្គការ ILO។ កម្មការិនី

មានផ្ទៃពោះទទួលបានតាវកាលិកពិសេស។ ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់ប្រជាជនចំនួន ១,៥លាននាក់ ត្រូវបានដាក់ឱ្យអនុវត្តនៅខែវិច្ឆិកា ឆ្នាំ ២០២៣ ដើម្បីផ្តល់ជំនាញ ពង្រឹងជំនាញ និងរៀនជំនាញថ្មី។

៥៨. របបសន្តិសុខសង្គមត្រូវបានដាក់ឱ្យអនុវត្តសម្រាប់ពលករ ក្នុងវិស័យដឹកជញ្ជូនតាមផ្លូវអាកាស និងនាវាសមុទ្រ អ្នកបម្រើការងារតាមផ្ទះ និងបុគ្គលស្វ័យនិយោជន៍ នៅក្រោមបេឡាសន្តិសុខសង្គមជាតិ។ ការរួមវិភាគទានក្នុងផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងារ បានទទួលការទូទាត់ពេញលេញពីនិយោជក ខណៈដែលផ្នែកប្រាក់សោធនត្រូវបានបង់រួមគ្នាពីនិយោជក និងនិយោជិត។ ការសិក្សាលទ្ធភាពដើម្បីអនុវត្តផ្នែកនិកម្មភាពការងារ ត្រូវបានអនុវត្ត។

៥៩. ការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងពលកម្មដោយបង្ខំ ព្រមទាំងការកេងប្រវ័ញ្ចផ្លូវភេទនៅតែជាអាទិភាពខ្ពស់បំផុតសម្រាប់កម្ពុជា។ ពីឆ្នាំ២០១៩ ដល់ឆ្នាំ ២០២៣ អាជ្ញាធរមានសមត្ថកិច្ចបានបង្ក្រាបករណីពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទចំនួន ៩៣៦ករណី ចាប់ខ្លួនជនសង្ស័យចំនួន ១.២៥៨នាក់ និងជួយសង្គ្រោះជនរងគ្រោះចំនួន ៣.១៣៩នាក់។ កម្ពុជាបានរៀបចំផែនការយុទ្ធសាស្ត្រដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សសម្រាប់ឆ្នាំ២០២៤-២០២៨។

៦០. ទោះបីជាកម្ពុជាមិនទាន់មានគោលនយោបាយ និងក្របខណ្ឌច្បាប់ជាក់លាក់ចំពោះសិទ្ធិបុរសស្រឡាញ់បុរស ស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរយេនឌ័រ ក៏ដោយ ក្រមព្រហ្មទណ្ឌបានចែងអំពីកិច្ចការពារបុគ្គលទាំងអស់ពីការរើសអើងគ្រប់រូបភាព តាមរយៈមាត្រា ២៦៥ ដល់មាត្រា ២៧០ នៃក្រមនេះ។ កម្ពុជាមិនចាត់ទុកថាការស្រឡាញ់ភេទដូចគ្នាជាបទល្មើសឡើយ។ ដើម្បីឱ្យមានការធ្វើវិសោធនកម្មច្បាប់រដ្ឋប្បវេណីពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ភេទដូចគ្នា ចាំបាច់ត្រូវមានការតស៊ូមតិ និងការលើកកម្ពស់ការយល់ដឹងជាសាធារណៈបន្ថែមទៀត ដើម្បីបង្កើនការយល់ដឹង និងការទទួលយកពីសង្គម។

៦១. ប៉ូឡូញ ស្វាគមន៍កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ។

៦២. ព័រទុយហ្គាល់ ស្វាគមន៍ដែលកម្ពុជាអនុម័ត ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ និងគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ។

៦៣. សាធារណរដ្ឋកូរ៉េ កោតសរសើរកម្ពុជាចំពោះការកាត់បន្ថយអត្រាភាពក្រីក្រ និងការថយចុះនៃអត្រាមរណភាពទារក និងកុមារ។

៦៤. សហព័ន្ធរុស្ស៊ីកត់ សម្គាល់ការប្រសើរឡើងនៃប្រព័ន្ធអភិបាលកិច្ចរដ្ឋ និងយុត្តិធម៌ ព្រមទាំងវិធានការប្រយុទ្ធប្រឆាំងអំពើពុករលួយ។

៦៥. អារ៉ាប៊ីសាអូឌីត ស្វាគមន៍កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ទឹកបរិភោគដែលមានសុវត្ថិភាព ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

៦៦. សេណេហ្គាល់ ទទួលស្គាល់កិច្ចសហការរបស់កម្ពុជា ជាមួយនឹង OHCHR និងលើកទឹកចិត្តឱ្យកម្ពុជាបន្តកិច្ចសហប្រតិបត្តិការនេះ។

៦៧. ស៊ែប៊ី កោតសរសើរកម្ពុជា ចំពោះការកាត់បន្ថយអត្រាភាពក្រីក្រគួរឱ្យកត់សម្គាល់។

៦៨. សៀរ៉ាឡេអូន កោតសរសើរចំពោះសេចក្តីសម្រេចរបស់កម្ពុជាក្នុងការបន្ត MOU ជាមួយ OHCHR សម្រាប់រយៈពេលពីរឆ្នាំបន្ថែមទៀត។

៦៩. សិង្ហបុរី កត់សម្គាល់នូវនិន្នាការវិជ្ជមាន ក្នុងការកាត់បន្ថយអត្រាមរណភាពមាតា កុមារ និងទារករបស់កម្ពុជា។

៧០. ស្លូវេនី កត់សម្គាល់វិធានការក្នុងការសម្រេចបានសមភាពយេនឌ័រក្នុងវិស័យដីធ្លី។ ប្រទេសនេះនៅបន្តព្រួយបារម្ភពីអត្រាភាពអត់ការងារធ្វើខ្ពស់របស់ស្ត្រីនៅតាមតំបន់ជនបទ។ ប្រទេសនេះជំរុញកម្ពុជាឱ្យធានានូវលំហពលរដ្ឋដោយសេរី។

៧១. អេស្ប៉ាញ កោតសរសើរកម្ពុជា ចំពោះការបញ្ចូលទស្សនៈយេនឌ័រក្នុងកិច្ចផ្តួចផ្តើមថ្មីៗ។

៧២. ស្រីលង្កា ស្វាគមន៍វិធានការនានា ដែលត្រូវបានអនុវត្ត ដើម្បីលើកកម្ពស់សិទ្ធិស្ត្រី និងកុមារ។

៧៣. ស៊ូដង់ ស្វាគមន៍វិធានការរបស់កម្ពុជា ក្នុងការឆ្លើយតបចំពោះសិទ្ធិស្ត្រី ពលកម្មកុមារ ពិការភាព អំពើជួញដូរមនុស្ស ជំងឺរបេង និងអំពើពុករលួយ។

៧៤. ស៊ុយអែត កត់សម្គាល់វឌ្ឍនភាពនៃសិទ្ធិការងារ និងសិទ្ធិសហជីព។ ប្រទេសនេះព្រួយបារម្ភចំពោះស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ជាពិសេស ពាក់ព័ន្ធនឹងសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពនៃការប្រមូលផ្តុំ។

៧៥. ស្វីស ផ្តល់អនុសាសន៍មួយចំនួន។

៧៦. សាធារណរដ្ឋស៊ីរី ស្វាគមន៍ផលជះវិជ្ជមាន នៃកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងតួនាទីរបស់កម្មវិធីទាំងនេះក្នុងការកាត់បន្ថយភាពក្រីក្រ។

៧៧. ថៃ ស្វាគមន៍វឌ្ឍនភាពរបស់កម្ពុជាក្នុងការដោះស្រាយវិសមភាពយេនឌ័រ និងកិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយផលវិបាកផ្នែកមនុស្សធម៌ ដោយសារគ្រាប់មីនប្រឆាំងមនុស្សជាតិ។

៧៨. ទីម័រខាងកើត កត់សម្គាល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការសម្រេចបាន សមភាពយេនឌ័រ ពង្រឹងគុណភាព និងលទ្ធភាពទទួលបានការអប់រំ និងពង្រីកការគ្រប ដណ្តប់នៃកិច្ចគាំពារសង្គម។

៧៩. តូហ្គោ ស្វាគមន៍វិធានការនានាដើម្បីលើកកម្ពស់សិទ្ធិទទួលបានការអប់រំ និង ការថែទាំសុខភាព សិទ្ធិស្ត្រី សិទ្ធិកុមារ សិទ្ធិជនមានពិការភាព និងសិទ្ធិរបស់ជនជាតិដើម ភាគតិច។

៨០. តួកគី កោតសរសើរកម្ពុជាចំពោះកិច្ចខិតខំប្រឹងប្រែង និងសមិទ្ធផលក្នុងការ លើកកម្ពស់សុខដុមនីយកម្មសាសនា និងការចូលរួមបែបស្ថាបនាជាមួយអ្នករាយការណ៍ ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។

៨១. អ៊ុយក្រែន កត់សម្គាល់វឌ្ឍនភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាល និងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី។

៨២. ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង ស្វាគមន៍ជំហានក្នុងបង្ក្រាបការបោក ប្រាស់តាមប្រព័ន្ធអនឡាញ ប៉ុន្តែនៅបន្តព្រួយបារម្ភចំពោះការអនុវត្តច្បាប់ដោយគ្មាន សង្គតិភាព។

៨៣. សាធារណរដ្ឋសហភាពតង់សានី ស្វាគមន៍ការប្រកាសឱ្យអនុវត្តន៍ផែនការ សកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងពលកម្មកុមារ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការ ភាព ២០១៩-២០២៣។

៨៤. សហរដ្ឋអាមេរិក ជំរុញឱ្យកម្ពុជាគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឱ្យបាន ពេញលេញ និងស្តារលទ្ធិប្រជាធិបតេយ្យពហុបក្សឡើងវិញ។

៨៥. អ៊ុយរូហ្គាយ ផ្តល់អនុសាសន៍មួយចំនួន។

៨៦. វ៉ានូទូ ស្វាគមន៍កិច្ចខិតខំប្រឹងប្រែងគួរឱ្យកត់សម្គាល់ របស់កម្ពុជាឆ្ពោះទៅរកការ សម្រេចបានសកលកម្មទឹកបរិភោគដែលមានសុវត្ថិភាព និងថ្លៃសមរម្យ។

៨៧. វេណេស៊ុយអេឡា ស្វាគមន៍វឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការកាត់បន្ថយភាព ក្រីក្រ បង្កើនគុណភាពនៃការអប់រំ និងបង្កើនកម្រិតជីវភាពរស់នៅរបស់ប្រជាជន។

៨៨. វៀតណាម កោតសរសើរកម្ពុជាចំពោះកិច្ចខិតខំប្រឹងប្រែង ក្នុងការបង្កើន សមភាពយេនឌ័រ និងលើកកម្ពស់ភាពអង់អាចផ្នែកសង្គម និងសេដ្ឋកិច្ចដល់ស្ត្រី។

៨៩. យេម៉ែន កោតសរសើរការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះសិទ្ធិមនុស្ស កំណែទម្រង់ អភិបាលកិច្ច ការអភិវឌ្ឍ ការប្រឆាំងអំពើពុករលួយ កិច្ចសហប្រតិបត្តិការជាមួយអង្គភាព អន្តរជាតិ។

៩០. សំប៊ី ស្វាគមន៍កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងកំណែទម្រង់អភិបាលកិច្ច ទំនើបកម្មស្ថាប័នរដ្ឋ និងការអភិវឌ្ឍប្រកបដោយចីរភាព។

៩១. ស៊ីមបាវ៉េ កោតសរសើរកម្ពុជាចំពោះការអនុវត្តអនុសាសន៍ ដែលទទួលបានពីការពិនិត្យឡើងវិញជាសកលតាមកាលកំណត់លើកមុន ដែលបានរួមចំណែកក្នុងការពង្រឹងប្រព័ន្ធកិច្ចការពារសិទ្ធិមនុស្សជាតិ។

៩២. អាល់ហ្សេរី កោតសរសើរកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការកាត់បន្ថយវិសមភាព និងអត្រាភាពក្រីក្រ ព្រមទាំងធានាលទ្ធភាពជាសកលក្នុងការទទួលបានប្រព័ន្ធថែទាំសុខភាព និងអប់រំ។

៩៣. អាហ្សង់ទីន ផ្ដល់អនុសាសន៍មួយចំនួន។

៩៤. អាមេនី ស្វាគមន៍ការអនុវត្តផែនការសកម្មភាពជាតិស្តីពី ការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (២០១៦-២០២៥)។

៩៥. អូស្ត្រាលី កោតសរសើរកម្ពុជាចំពោះវឌ្ឍនភាពស្តីពីសមភាពយេនឌ័រ បរិយាបន្នសង្គម និងសិទ្ធិ LGBTQIA+។

៩៦. កម្ពុជាថ្លែងថា សិទ្ធិទទួលបានព័ត៌មាន មានការធានាពីរដ្ឋធម្មនុញ្ញ។ កម្ពុជាកំពុងរៀបចំបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន។ ស្ថាប័នព័ត៌មានជាង ២.០០០ និងអ្នកសារព័ត៌មាន ១០.០០០នាក់ រួមទាំងអ្នករិះគន់រដ្ឋាភិបាល កំពុងធ្វើប្រតិបត្តិការដោយសេរី ដោយពុំមានការត្រួតពិនិត្យជាមុនលើការបោះពុម្ពផ្សាយ។

៩៧. ទោះបីជាកម្ពុជាគាំទ្រសារព័ត៌មានសេរី និងឯករាជ្យ ក៏កម្ពុជាចាំបាច់ត្រូវប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត និងក្លែងក្លាយក្នុងចេតនាព្យាបាទ និងជំរុញដោយសារផលប្រយោជន៍នយោបាយដើម្បីញុះញង់ឱ្យមានការស្អប់ខ្ពើម និងអំពើហិង្សាដែលរំខានដល់ស្ថិរភាពសង្គម ទន្ទឹមនឹងនោះក៏បង្កអន្តរាយចំពោះគោលការណ៍សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។

៩៨. កម្ពុជាផ្តល់លំហដ៏រស់រវើកសម្រាប់សង្គមស៊ីវិល។ បច្ចុប្បន្ន មានអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិជាង ៦.០០០ បានចុះបញ្ជីនៅកម្ពុជា។ កម្ពុជាប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់ភាពជាដៃគូពិតប្រាកដជាមួយសង្គមស៊ីវិល ក្នុងគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍសង្គម។

៩៩. កម្ពុជាជឿជាក់មុតមាំលើប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន។ ប្រព័ន្ធនេះត្រូវបានឆ្លុះបញ្ចាំងក្នុងការបោះឆ្នោតនីតិកាលទី ៧ នៃរដ្ឋសភា នៅឆ្នាំ២០២៣ ដែលត្រូវបានធ្វើឡើងដោយសេរី យុត្តិធម៌ សន្តិភាព និងតម្លាភាព ដោយមានចំនួនអ្នកទៅបោះឆ្នោតយ៉ាងច្រើន (៨៤,៥%)។

១០០. ដើម្បីធានា និងពង្រឹងឯករាជ្យភាពតុលាការ កម្ពុជាអនុម័តច្បាប់សំខាន់ៗចំនួនបី រួមមាន ច្បាប់ស្តីពីការរៀបចំអង្គតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ អំណាចតុលាការ គឺជាអំណាចឯករាជ្យ និងគ្មានស្ថាប័នណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬ

នីតិប្រតិបត្តិអាចជ្រៀតជ្រែកការងាររបស់តុលាការបានឡើយ។ អង្គភាពដោះស្រាយវិវាទថ្មីមួយត្រូវបានបង្កើតឡើង ដើម្បីកាត់បន្ថយការកកស្ទះសំណុំរឿងតុលាការ។ គណៈកម្មាធិការដឹកនាំកំណែទម្រង់យុត្តិធម៌ថ្មីមួយត្រូវបានបង្កើត ដើម្បីដឹកនាំ ធ្វើសន្ធានកម្ម និងលើកកម្ពស់ការអនុវត្តកំណែទម្រង់ប្រព័ន្ធយុត្តិធម៌។

១០១. អាស៊ែបៃហ្សង់ ស្វាគមន៍ការប្រកាសឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព និងកិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់សិទ្ធិជនមានពិការភាព។

១០២. បារ៉ែន ទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងដែលកម្ពុជាបានធ្វើ ក្នុងការពិនិត្យឡើងវិញលើច្បាប់ និងអនុវត្តកំណែទម្រង់ច្បាប់ដោយអនុលោមតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។

១០៣. បង់ក្លាដែស ទទួលស្គាល់វឌ្ឍនភាព និងសមិទ្ធផលគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍជនបទ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។

១០៤. បេឡារុស កត់សម្គាល់លទ្ធផលដែលកម្ពុជាសម្រេចបាន ដើម្បីធានាវឌ្ឍនភាពសេដ្ឋកិច្ចសង្គម គាំទ្រប្រជាជនងាយរងគ្រោះ និងពង្រីកការទទួលបានការអប់រំ និងការថែទាំសុខភាព។

១០៥. បែលហ្ស៊ិក អបអរសាទរកម្ពុជាចំពោះវឌ្ឍនភាពនៃកិច្ចគាំពារសង្គម ប៉ុន្តែជឿជាក់ថាកម្ពុជាអាចសម្រេចកិច្ចការបានជាច្រើនទៀត។

១០៦. ប៊ូតង់ កត់សម្គាល់វិធានការ ដើម្បីបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស និងលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងកុមារី។

១០៧. បូលីវី ស្វាគមន៍គោលនយោបាយរបស់កម្ពុជា ស្តីពីការចុះបញ្ជីសិទ្ធិប្រើប្រាស់ដីរបស់ជនជាតិដើមភាគតិច និងកម្មវិធីអប់រំពហុភាសាសម្រាប់កុមារា និងកុមារីជនជាតិដើមភាគតិច។

១០៨. ប្រេស៊ីល កោតសរសើរកម្ពុជាចំពោះភាពរីកចម្រើន ពាក់ព័ន្ធនឹងការលុបបំបាត់ភាពក្រីក្រ និងសង្កត់ធ្ងន់លើគំនិតផ្តួចផ្តើមដើម្បីលើកទឹកចិត្តកុមារីឱ្យចូលរៀន។

១០៩. ព្រុយណេទទួលស្គាល់ការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងវិស័យសុខភាពសាធារណៈ និងការគ្របដណ្តប់សុខភាពជាសកល។

១១០. ប៊ុលហ្គារី ស្វាគមន៍ផែនការជាតិក្នុងវិស័យសំខាន់ៗ ដូចជា ការថែទាំសុខភាព អំពើហិង្សាលើស្ត្រី និងពលកម្មកុមារ។

១១១. បួគីណាហ្វាសូ កោតសរសើរកម្ពុជា ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងវិស័យពលកម្មកុមារ និងវិធានការដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

១១២. កាមេរូន សាទរចំពោះជំហានដែលកម្ពុជាបានអនុវត្ត ដើម្បីបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស។

១១៣. កាណាដា បង្ហាញការព្រួយបារម្ភពាក់ព័ន្ធនឹងការបន្តបង្ក្រាបសំឡេងប្រឆាំងនៅកម្ពុជា។

១១៤. ស៊ីលី អបអរសាទរកម្ពុជាដែលប្រកាសដាក់ឱ្យអនុវត្តនូវផែនការយុទ្ធសាស្រ្តជាតិ ស្តីពីពិការភាព (២០១៩-២០២៣)។

១១៥. ចិន ទទួលស្គាល់កិច្ចខិតខំប្រឹងប្រែង ដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រ និងការបង្កើនកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

១១៦. កូឡុំប៊ី ផ្តល់អនុសាសន៍មួយចំនួន។

១១៧. កូស្តារីកា សាទរកិច្ចសហប្រតិបត្តិការរបស់កម្ពុជា ជាមួយនីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។

១១៨. ក្រូអាស៊ី លើកទឹកចិត្តកម្ពុជាឱ្យផ្តល់ និងបើកលំហនយោបាយ សេរីភាពពីការគំរាមកំហែង និងការបំភិតបំភ័យ។

១១៩. គុយបា គូសបញ្ជាក់នូវសមិទ្ធផលក្នុងការកាត់បន្ថយភាពក្រីក្រ កំណែទម្រង់អភិបាលកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។

១២០. ស៊ីប ស្វាគមន៍កិច្ចខិតខំប្រឹងប្រែងដើម្បីការពារជនមានពិការភាព។

១២១. សាធារណរដ្ឋឆែក កោតសរសើរកម្ពុជា ចំពោះកិច្ចសហប្រតិបត្តិការជាមួយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។

១២២. សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ កោតសរសើរកម្ពុជាចំពោះវឌ្ឍនភាពក្នុងការអភិវឌ្ឍប្រកបដោយចីរភាព។

១២៣. ដាណឺម៉ាក កត់សម្គាល់ថានៅមានការព្រួយបារម្ភ អំពីការរំលាយគណបក្សនយោបាយ និងការបិទប្រព័ន្ធផ្សព្វផ្សាយ។

១២៤. សាធារណរដ្ឋដូមីនីក កោតសរសើរកម្ពុជាចំពោះការអនុវត្តផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (២០១៦-២០២៥)។

១២៥. អេហ្ស៊ីប ស្វាគមន៍កិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់កម្ពុជា ក្នុងការផ្តល់សច្ចាប័នលើលិខិតុបករណ៍អន្តរជាតិ ព្រមទាំងកិច្ចសហប្រតិបត្តិការជាមួយយន្តការសិទ្ធិមនុស្ស។

១២៦. អេស្តូនី នៅបន្តមានការព្រួយបារម្ភចំពោះការបំបិទលំហប្រជាធិបតេយ្យ និងពលរដ្ឋ។

១២៧. អេត្យូពី កោតសរសើរកម្ពុជាចំពោះការអនុវត្តអនុសាសន៍ដែលទទួលបានក្នុងការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ពីវគ្គមុនៗ។

១២៨. ហ្វាំងឡង់ កត់សម្គាល់ជាវិជ្ជមានថាកម្ពុជាបានរៀបចំទទួលអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។

១២៩. បារាំង កោតសរសើរកិច្ចសហប្រតិបត្តិការរបស់កម្ពុជាជាមួយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។

១៣០. ហ្គំប៊ី កោតសរសើរកម្ពុជា ចំពោះការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សប្រាំបីក្នុងចំណោមសន្ធិសញ្ញាសិទ្ធិមនុស្សស្នូលទាំងប្រាំបួន។

១៣១. ហ្សកហ្ស៊ី ទទួលស្គាល់វឌ្ឍនភាពរបស់កម្ពុជានៅក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

១៣២. អាល្លឺម៉ង់ កត់សម្គាល់ថានៅមានការព្រួយបារម្ភចំពោះលក្ខខណ្ឌការងាររបស់អង្គការសង្គមស៊ីវិល។

១៣៣. ហ្កាណា អបអរសាទរកម្ពុជា ចំពោះការប្រកាសឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣។

១៣៤. អ៊ីស្លង់ ផ្តល់អនុសាសន៍មួយចំនួន។

១៣៥. ឥណ្ឌា សាទរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស។

១៣៦. ឥណ្ឌូនេស៊ី កោតសរសើរកម្ពុជា ចំពោះការជំរុញយ៉ាងសកម្មនូវកិច្ចសហប្រតិបត្តិការដ៏ស្វាហាប់ជាមួយយន្តការសិទ្ធិមនុស្ស រួមទាំង OHCHR ដែរ។

១៣៧. គណៈប្រតិភូកម្ពុជាបានថ្លែងថា កម្ពុជានឹងពិចារណាផ្តល់សច្ចាប័នលើពិធីសារបន្ថែមទីពីរនៃ ICCPR ដែលសំដៅលុបបំបាត់ទោសប្រហារជីវិត ប៉ុន្តែគួសបញ្ជាក់ថា រដ្ឋធម្មនុញ្ញរបស់កម្ពុជាបានចែងពីការហាមឃាត់ទោសប្រហារជីវិត។ កម្ពុជាយកចិត្តទុកដាក់ខ្លាំងចំពោះបញ្ហាបោកប្រាស់តាមប្រព័ន្ធអនឡាញ និងសង្ឃឹមថាសេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខប្រព័ន្ធបច្ចេកវិទ្យា និងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា នឹងកាន់តែជួយការងារប្រយុទ្ធប្រឆាំងចំពោះបទល្មើសបែបនេះបន្ថែមទៀត។

១៣៨. កម្ពុជានៅតែប្តេជ្ញាចិត្តចំពោះការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស ដោយអនុលោមតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជា និងបរិបទជាតិរបស់ខ្លួន។ កម្ពុជា តាមរយៈកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ នឹងពិចារណាឱ្យបានម៉ត់ចត់លើអនុសាសន៍នៃការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ ដែលទទួលបាន និងពិចារណារកវិធីអនុវត្តអនុសាសន៍ទាំងនេះ និងធ្វើយ៉ាងណាដើម្បីរួមចំណែកឱ្យបានល្អបំផុតចំពោះការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សនៅកម្ពុជា និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា។

# II. សេចក្តីសន្និដ្ឋាន និង/ឬអនុសាសន៍

១៣៩. អនុសាសន៍ខាងក្រោមនឹងត្រូវពិនិត្យដោយកម្ពុជា ហើយដែលនឹងផ្តល់ចម្លើយតាមពេលវេលាកំណត់ ប៉ុន្តែមិនត្រូវហួសសម័យប្រជុំលើកទីហាសិបប្រាំពីរនៃក្រុមប្រឹក្សាសិទ្ធិមនុស្សឡើយ ៖

១៣៩.១ ផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពី ការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែមទីពីរនៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សំដៅលុបបំបាត់ទោសប្រហារជីវិត (កូឡុំប៊ី) (ប៉ារ៉ាហ្គាយ)។

១៣៩.២ ផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ (ហ្គាណា) ចូលជាសមាជិកនៃ អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ (ហ្គំប៊ី)។

១៣៩.៣ ពិចារណាផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិ ស្តីពី ការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ (សេណេហ្គាល់)។

១៣៩.៤ ពិចារណាផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិ ស្តីពី ការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ និងពិធីសារបន្ថែមនៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (បូលីវី)។

១៣៩.៥ ផ្តល់សច្ចាប័នលើលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ រួមមានជាអាទិ៍ ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែមទីពីរនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សំដៅលុបបំបាត់ទោសប្រហារជីវិត (អ៊ុយក្រែន)។

១៣៩.៦ ផ្តល់សច្ចាប័នលើពិធីសារបន្ថែមទីពីរ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក្នុងគោលបំណងលុបបំបាត់ទោសប្រហារជីវិត (ស៊ីលី) (ស៊ីប) (បារាំង) (ម៉ាល់ត៍)។

១៣៩.៧ ផ្តល់សច្ចាប័នលើពិធីសារបន្ថែមទីពីរ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក្នុងគោលបំណងលុបបំបាត់ទោសប្រហារជីវិត (លិចតិនស្តាញ)។

១៣៩.៨ ផ្តល់សច្ចាប័នលើពិធីសារបន្ថែមទីពីរ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលមានបំណងលុបបំបាត់ទោសប្រហារជីវិត (កូស្តារីកា)។

១៣៩.៩ ពិចារណាផ្តល់សច្ចាប័នលើពិធីសារបន្ថែមទីពីរ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សំដៅលុបបំបាត់ទោសប្រហារជីវិត (នេប៉ាល់)។

១៣៩.១០ ផ្តល់សច្ចាប័នលើពិធីសារបន្ថែម នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (អាមេនី)។

១៣៩.១១ ផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិរបស់ជនមានពិការភាព (បួគីណាហ្វាសូ)។

១៣៩.១២ ពិចារណាផ្តល់សច្ចាប័នលើពិធីសារបន្ថែម នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងនីតិវិធីបណ្តឹង (អាមេនី)។

១៣៩.១៣ ផ្តល់សច្ចាប័នលើពិធីសារបន្ថែម នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងនីតិវិធីបណ្តឹង និងបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងការទទួលបានយុត្តិធម៌របស់កុមារ (ម៉ារ៉ុក)។

១៣៩.១៤ ផ្តល់សច្ចាប័នលើវិសោធនកម្មលើលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ស្តីពីបទឧក្រិដ្ឋឈ្លានពាន (លិចតិនស្តាញ)។

១៣៩.១៥ ផ្តល់សច្ចាប័នលើអនុសញ្ញាពាក់ព័ន្ធនឹងឋានៈរបស់ជនគ្មានរដ្ឋ និងអនុសញ្ញាស្តីពីការកាត់បន្ថយភាពគ្មានរដ្ឋ (បួគីណាហ្វាសូ) (កូឡុំប៊ី)។

១៣៩.១៦ ផ្តល់សច្ចាប័នលើអនុសញ្ញាពាក់ព័ន្ធនឹងឋានៈរបស់ជនគ្មានរដ្ឋ និងពិធីសារបន្ថែមទីពីរនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សំដៅលុបបំបាត់ទោសប្រហារជីវិត (អេស្ប៉ាញ)។

១៣៩.១៧ ផ្តល់សច្ចាប័នលើអនុសញ្ញា ប្រឆាំងនឹងការរើសអើងក្នុងវិស័យអប់រំដែលត្រូវបានផ្តល់អនុសាសន៍ដោយ អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ (អង្គការយូណេស្កូ) (ម៉ូរីស)។

១៣៩.១៨ ពិចារណាផ្តល់សច្ចាប័នលើអនុសញ្ញា ប្រឆាំងនឹងការរើសអើងក្នុងវិស័យអប់រំ (សេណេហ្គាល់)។

១៣៩.១៩ បន្តកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអង្គការសហប្រជាជាតិ និងយន្តការនានារបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (គៀហ្ស៊ីស៊ីស្ថាន)។

១៣៩.២០ បន្តកិច្ចសហការជាមួយយន្តការសិទ្ធិមនុស្សនានា របស់អង្គការសហប្រជាជាតិ ជាពិសេស ជាមួយ OHCHR (ម៉ាឡេស៊ី)។

១៣៩.២១ បន្តកិច្ចសហប្រតិបត្តិការជាមួយយន្តការអង្គការសហប្រជាជាតិ (អាល់ហ្សេរី)។

១៣៩.២២ បន្តការចូលរួមនិងកិច្ចសហប្រតិបត្តិការជាមួយយន្តការសិទ្ធិមនុស្ស និងនីតិវិធីពិសេស ដើម្បីការពារ និងលើកកម្ពស់បទដ្ឋាន និងគោលការណ៍សិទ្ធិមនុស្សនៅកម្ពុជា (សៀរ៉ាឡេអូន)។

១៣៩.២៣ សហប្រតិបត្តិការពេញលេញជាមួយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ជាពិសេស ការអនុវត្តអនុសាសន៍របស់អ្នករាយការណ៍ពិសេស ដែលបានបានធ្វើបទបង្ហាញក្នុងឆ្នាំ២០២៣ (លុចសំបួ)។

១៣៩.២៤ បន្តអនុវត្តអនុសាសន៍នានា ដែលត្រូវបានស្នើឡើងក្នុងការពិនិត្យឡើងវិញលើកនេះ ដោយប្រកាន់យកស្មារតីនៃយន្តការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ (សាធារណរដ្ឋតង់សានី)។

១៣៩.២៥ បន្តតម្រង់ទិសក្របខណ្ឌក្នុងប្រទេសឱ្យស្របតាមកាតព្វកិច្ច និងបទដ្ឋានអន្តរជាតិ រួមទាំងតាមរយៈការពន្លឿនការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស និងកំណែទម្រង់តុលាការ (ហ្វីលីពីន)។

១៣៩.២៦ រក្សាការគាំទ្ររបស់ខ្លួនក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស (តួកគី)។

១៣៩.២៧ បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងក្របខណ្ឌច្បាប់ជាតិ ដោយអនុលោមតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា (រុស្ស៊ី)។

១៣៩.២៨ បន្តពង្រឹងក្របខណ្ឌជាតិ និងក្របខណ្ឌច្បាប់របស់ខ្លួន ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស (អេត្យូពី)

១៣៩.២៩ បន្តកិច្ចខិតខំប្រឹងប្រែងលើការងារ កំណែទម្រង់ប្រព័ន្ធនីតិប្បញ្ញត្តិ និងច្បាប់ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស (ស៊ូដង់)។

១៣៩.៣០ ធានាថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចរក្សាឯករាជ្យភាព និងមុខងាររបស់ខ្លួន ក្នុងនាមជាស្ថាប័នជាតិប្រកបដោយប្រសិទ្ធភាពក្នុងការដោះស្រាយវិវាទឱ្យបានទាន់ពេលវេលា (ស៊ុយអែត)។

១៣៩.៣១ ធានាថា ច្បាប់ និងការអនុវត្តច្បាប់មានសង្គតិភាពនឹងកាតព្វកិច្ចអន្តរជាតិ រួមទាំងតាមរយៈការពិនិត្យឡើងវិញលើច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពី សហជីព និងនិវាករណ៍ វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោត ឆ្នាំ២០២៣ និងវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ឆ្នាំ២០១៧ (អូស្ត្រាលី)។

១៣៨.៣២ ពន្លឿនកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើត ស្ថាប័នជាតិសិទ្ធិមនុស្ស ដោយអនុលោមទៅតាមគោលការណ៍ទីក្រុងប៉ារីស (អ៊ីរ៉ាក់) ពន្លឿនកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ស្របតាមគោលការណ៍ទីក្រុងប៉ារីស (ហ្គំប៊ី) បន្ត និងរៀបចំបញ្ចប់ដំណើរការនៃការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ដោយអនុលោមទៅតាមគោលការណ៍ទីក្រុងប៉ារីស (កាមេរូន) បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្សដោយអនុលោមតាមគោលការណ៍ទីក្រុងប៉ារីស (បង់ក្លាដែស) បន្តពន្លឿនការងារឆ្ពោះទៅរកការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ដោយអនុលោមទៅតាមគោលការណ៍ទីក្រុងប៉ារីស (វេណេស៊ុយអេឡា)។

១៣៩.៣៣ ពន្លឿនកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើត ស្ថាប័នជាតិសិទ្ធិមនុស្សឯករាជ្យ ដោយអនុលោមទៅតាមគោលការណ៍ទីក្រុងប៉ារីស (កូស្តារីកា)។

១៣៩.៣៤ ពន្លឿនការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ដែលមានអនុលោមភាពពេញលេញស្របតាមគោលការណ៍ទីក្រុងប៉ារីស ផ្តល់នូវធនធានចាំបាច់ដើម្បីឱ្យស្ថាប័ននេះធ្វើការងារដោយឯករាជ្យ និងមានសុវត្ថិភាព (លុចសំបួ)។

១៣៩.៣៥ ពន្លឿនដំណើរការក្នុងការបង្កើត ស្ថាប័នជាតិសិទ្ធិមនុស្សដោយអនុលោមទៅតាមគោលការណ៍ទីក្រុងប៉ារីស (ម៉ុងហ្គោលី)។

១៣៩.៣៦ ពន្លឿនការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ (ហ្គាណា)។

១៣៩.៣៧ រៀបចំបញ្ចប់កិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើត ស្ថាប័នជាតិសិទ្ធិមនុស្ស (ស៊ូដង់)។

១៣៩.៣៨ បញ្ចប់ដំណើរការការងារ សំដៅពង្រឹងស្ថាប័នជាតិសិទ្ធិមនុស្សដែលអនុលោមទៅតាមគោលការណ៍ទីក្រុងប៉ារីស (តូហ្គោ)។

១៣៩.៣៩ បន្តកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកការបង្កើត ស្ថាប័នជាតិសិទ្ធិមនុស្ស តាមរយៈការរៀបចំបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នជាតិសិទ្ធិមនុស្ស (ទីម័រខាងកើត)។

១៣៩.៤០ បន្តកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងស្ថាប័នជាតិសិទ្ធិមនុស្ស ស្របទៅតាមគោលការណ៍ទីក្រុងប៉ារីស (នេប៉ាល់)។

១៣៩.៤១ បន្តកិច្ចខិតខំប្រឹងប្រែង ក្នុងការធ្វើឱ្យប្រសើរឡើងនូវតួនាទីរបស់គណៈកម្មការជាតិសិទ្ធិមនុស្ស និងសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (យេម៉ែន)។

១៣៩.៤២ បង្កើតយន្តការជាតិសម្រាប់ការអនុវត្ត ការរាយការណ៍ និងការតាមដានអនុសាសន៍សិទ្ធិមនុស្ស ដោយពិចារណាលើលទ្ធភាពនៃការទទួលកិច្ចសហប្រតិបត្តិការ ឆ្លើយតបនឹងគោលបំណងនេះ (ប៉ារ៉ាហ្គាយ)។

១៣៩.៤៣ អនុម័តច្បាប់ប្រឆាំងការរើសអើងគ្រប់ជ្រុងជ្រោយ ដើម្បីធានាកិច្ចការពារពេញលេញ និងដោយប្រសិទ្ធភាពប្រឆាំងរាល់ទម្រង់នៃការរើសអើងក្នុងគ្រប់វិស័យទាំងអស់ (អេស្តូនី)។

១៣៩.៤៤ បង្កើតច្បាប់ប្រឆាំងការរើសអើងជាក់លាក់ សម្រាប់ការការពារជនជាតិភាគដើមតិច (ក្រូអាស៊ី)។

១៣៩.៤៥ បង្កើនការប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការរើសអើង ជាពិសេសទៅលើស្ត្រី ជនមានពិការភាព និងជនជាតិដើមភាគតិច (កាមេរូន)។

១៣៩.៤៦ បន្តកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់សិទ្ធិស្ត្រី កុមារ និងជនមានពិការភាព និងប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការរើសអើងលើពួកគេ (អេហ្ស៊ីប)។

១៣៩.៤៧ បង្កើនភាពតំណាង របស់ក្រុមដែលមិនសូវទទួលបានការយកចិត្តទុកដាក់ រួមទាំងស្ត្រីនៅក្នុងស្ថាប័នរដ្ឋាភិបាល (កាណាដា)។

១៣៩.៤៨ ពិចារណាកែលម្អដំណើរការ ការទទួលបានឯកសារអត្តសញ្ញាណ និងធានាការចុះបញ្ជីកំណើតជាសកល (ទីម័រខាងកើត)។

១៣៩.៤៩ បង្កើនកិច្ចខិតខំប្រឹងប្រែង សំដៅលើការស៊ើបអង្កេតដោយម៉ត់ចត់ ឯករាជ្យ និងឥតលម្អៀងចំពោះករណីការបាត់ខ្លួនដោយបង្ខំ និងផ្តល់ព័ត៌មានអំពីជោគវាសនារបស់ជនរងគ្រោះ (ស្វីស)។

១៣៩.៥០ ចាត់វិធានការ ដើម្បីស៊ើបអង្កេតពេញលេញលើការចោទប្រកាន់ថាមានអំពើទារុណកម្ម និងការប្រព្រឹត្តមិនគប្បី ដែលកើតឡើងក្នុងកន្លែងឃុំខ្លួនរបស់មន្ត្រីនគរបាល និងក្នុងកន្លែងឃុំខ្លួនផ្សេងទៀត ដែលក្នុងករណីខ្លះ បានបង្កឱ្យមានការបាត់បង់ជីវិត (ម៉ាល់ត៍)។

១៣៩.៥១ ស៊ើបអង្កេតបន្ទាន់ ចំពោះការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងទារុណកម្ម ការប្រព្រឹត្តមិនគប្បី និងការបាត់បង់ជីវិតនៅកន្លែងឃុំឃាំង និងធានាថា ជនរួចជីវិតពីទារុណកម្ម និងការប្រព្រឹត្តមិនគប្បី ព្រមទាំងគ្រួសាររបស់អ្នកដែលបានបាត់បង់ជីវិតនៅក្នុងកន្លែងឃុំឃាំង ទទួលបានសំណងខូចខាត និងសំណងជំងឺចិត្ត (ប៉ូឡូញ)។

១៣៩.៥២ ពន្លឿនកិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយករណីនៃការប្រើកម្លាំងហួសហេតុ និងការប្រព្រឹត្តមិនគប្បីមកលើជនជាប់ឃុំ ពីសំណាក់ភ្នាក់ងារអនុវត្តច្បាប់ (ឡេសូតូ)។

១៣៩.៥៣ កែលម្អលក្ខខណ្ឌនៃការឃុំខ្លួន ដែលស្របនឹងវិធានអង្គការសហប្រជាជាតិ ស្តីពី បទដ្ឋានអប្បបរមា សម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (វិធាននែលសាន់ ម៉ាន់ដឺឡា) ជាពិសេស ពាក់ព័ន្ធនឹងបទដ្ឋានគុណភាពខ្យល់ ការទទួលបានទឹកស្អាត និងអគ្គិសនីប្រើប្រាស់ (សំប៊ី)។

១៣៩.៥៤ បន្តចាត់វិធានការ ប្រយុទ្ធប្រឆាំងអំពើពុករលួយ រួមទាំងតាមរយៈការអប់រំ ការទប់ស្កាត់ និងការអនុវត្តច្បាប់ (អាស៊ែបៃហ្សង់)។

១៣៩.៥៥ បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយអំពើពុករលួយ និងធានាការទទួលបានយុត្តិធម៌សម្រាប់ផ្នែកទាំងអស់ក្នុងសង្គម (សាធារណរដ្ឋដូមីនីក)។

១៣៩.៥៦ បញ្ចប់អំពើពុករលួយ និងនិទណ្ឌភាពពាក់ព័ន្ធនឹងបញ្ហាដីធ្លី និងការពារអ្នករាយការណ៍ សាក្សី និងជនរងគ្រោះ (លុចសំបួ)។

១៣៩.៥៧ ពង្រឹងឯករាជ្យភាព និងគណនេយ្យភាពរបស់អង្គភាពប្រឆាំងអំពើពុករលួយ និងបង្កើតរបបរាយការណ៍ដែលមានកិច្ចការពារគ្រប់គ្រាន់សម្រាប់អ្នករាយការណ៍ ស្របទៅតាមការអនុវត្តល្អៗអន្តរជាតិ (សំប៊ី)។

១៣៩.៥៨ ជំរុញការស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្ស ដែលបានប្រព្រឹត្តក្នុងរបបពីអតីតកាល (កូឡុំប៊ី)។

១៣៩.៥៩ បន្តអនុវត្តវិធានការនានា ដើម្បីធានាឯករាជ្យភាពរបស់តុលាការ និងប្រព័ន្ធផ្សព្វផ្សាយ (អ៊ីតាលី)។

១៣៩.៦០ បន្តវិធានការកំណែទម្រង់ដែលកំពុងអនុវត្ត ដើម្បីពង្រឹងសក្តិសិទ្ធភាពរបស់ប្រព័ន្ធតុលាការនៅគ្រប់កម្រិត (ម៉ាឡាវី)។

១៣៩.៦១ អនុវត្តកំណែទម្រង់តុលាការ ដែលការពារឯករាជ្យភាព និងភាពមិនលម្អៀងនៃប្រព័ន្ធតុលាការ បុគ្គលិកតុលាការ និងចៅក្រម ដោយអនុលោមទៅតាមបទដ្ឋានអន្តរជាតិ (ន័រវែស)។

១៣៩.៦២ ពង្រឹងឯករាជ្យភាព និងសមត្ថភាពរបស់ អង្គភាពប្រឆាំងអំពើពុករលួយ និងបន្តអនុវត្តវិធានការ សំដៅធានាឯករាជ្យភាពរបស់តុលាការ (ស្វីស)។

១៣៩.៦៣ បន្តកំណែទម្រង់តុលាការ ដើម្បីសម្រេចបានចក្ខុវិស័យសម្រាប់ការទទួលបានយុត្តិធម៌សម្រាប់ជនគ្រប់រូប (ចិន)។

១៣៩.៦៤ ធានាថាគោលការណ៍ជំនុំជម្រះដោយយុត្តិធម៌ ជាពិសេស សិទ្ធិក្នុងការជួបជាមួយអ្នកនៅខាងក្រៅ គ្រួសារ និងមេធាវី ដូចមានចែងក្នុងច្បាប់ និងបទដ្ឋានអន្តរជាតិនានា ត្រូវបានគោរព និងលើកកម្ពស់ ក្នុងសំណុំរឿងទាំងអស់ (ហ្វាំងឡង់)។

១៣៩.៦៥ ចាត់វិធានការ ដើម្បីកែលម្អលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ជនគ្រប់រូប រួមទាំងជនជាតិភាគតិចនៅតំបន់ដាច់ស្រយាល (ស៊ីមបាវ៉េ)។

១៣៩.៦៦ បង្កើតប្រព័ន្ធគណនេយ្យភាពឯករាជ្យ ដើម្បីដោះស្រាយវិវាទដីធ្លីដោយយុត្តិធម៌ បរិយាបន្ន មានការចូលរួម ទាន់ពេល និងតម្លាភាព (អៀរឡង់)។

១៣៩.៦៧ ស្វែងរក និងអនុវត្តដំណោះស្រាយជាប្រព័ន្ធក្នុងការប្រយុទ្ធប្រឆាំងនឹងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា ជាពិសេស ក្នុងករណីទីតាំងឆបោកអនឡាញ (សាធារណរដ្ឋឆែក)។

១៣៩.៦៨ ការពារសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងជួបប្រជុំដោយសន្តិវិធី ជាពិសេស អ្នកនយោបាយពីគណបក្សប្រឆាំង អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ជាពិសេស អ្នកការពារសិទ្ធិដីធ្លី និងទប់ស្កាត់ការបំភិតបំភ័យចំពោះពួកគេ (លុចសំបួ)។

១៣៩.៦៩ ពង្រឹងកិច្ចខិតខំប្រឹងប្រែង ក្នុងការទប់ស្កាត់ការរំលោភសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សមាគម និងការប្រមូលផ្តុំដោយសន្តិវិធី ដូចមានធានាក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ឡេសូតូ)។

១៣៩.៧០ អនុវត្តកិច្ចការពារផ្លូវច្បាប់ ដើម្បីការពារសេរីភាពខាងការបញ្ចេញមតិ និងសមាគម រួមទាំង សង្គមស៊ីវិល (ម៉ាល់ត៍)។

១៣៩.៧១ ធានាសិទ្ធិទទួលបានសេរីភាពខាងការបញ្ចេញមតិ ព្រមទាំងសិទ្ធិសេរីភាពខាងការប្រមូលផ្តុំ និងសមាគម ដោយអនុលោមតាមកាតព្វកិច្ចអន្តរជាតិ ដើម្បីបង្កបរិយាកាសល្អប្រសើរសម្រាប់អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងសកម្មជននយោបាយ (អ៊ីតាលី)។

១៣៩.៧២ ធានាកិច្ចការពារ និងការលើកកម្ពស់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមទាំងសេរីភាពខាងការបញ្ចេញមតិ សារព័ត៌មាន ការប្រមូលផ្តុំ និងសមាគម ដើម្បីបង្កបរិយាកាសឱ្យប្រជាជនអាចបង្ហាញមតិយោបល់ផ្សេងៗដោយសេរី (ជប៉ុន)។

១៣៩.៧៣ ធានាសិទ្ធិសេរីភាពខាងការបញ្ចេញ សមាគម និងការប្រមូលផ្តុំដោយសន្តិវិធី និងបញ្ចប់សកម្មភាពចាប់ខ្លួន និងឃុំខ្លួនតាមទំនើងចិត្តចំពោះអ្នកការពារសិទ្ធិមនុស្ស អ្នកនយោបាយពីគណបក្សប្រឆាំង តំណាងសហជីព និងអ្នកសារព័ត៌មាន (ន័រវែស)។

១៣៩.៧៤ ចាត់វិធានការបន្ទាន់ និងដោយប្រសិទ្ធភាព ដើម្បីធានាថា បុគ្គលទាំងអស់ រួមទាំងអ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន អាចប្រើប្រាស់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសមាគម (ព័រទុយហ្គាល់)។

១៣៩.៧៥ ធានាសេរីភាពខាងការបញ្ចេញមតិ សមាគម និងការប្រមូលផ្តុំដោយសន្តិវិធី សម្រាប់ប្រជាជនគ្រប់រូប រួមទាំងអ្នកតំណាងពីគណបក្សនយោបាយ អ្នកសារព័ត៌មាន និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ ក្រុមធ្វើការក្នុងវិស័យការងារ អ្នកការពារសិទ្ធិមនុស្ស និងសង្គមស៊ីវិល (ហ្វាំងឡង់)។

១៣៩.៧៦ ដោះលែងអ្នកការពារសិទ្ធិមនុស្ស អ្នកនយោបាយពីគណបក្សប្រឆាំង អ្នកសារព័ត៌មាន និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ ទម្លាក់សំណុំរឿងតុលាការប្រឆាំងពួកគេ និងបញ្ឈប់ការបៀតបៀន ឬវាយប្រហារលើពួកគេ (ប៉ូឡូញ)។

១៣៩.៧៧ ពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីទប់ស្កាត់ការបៀតបៀន និងការពារសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន (សាធារណរដ្ឋឆែក)។

១៣៩.៧៨ បញ្ឈប់ការបៀតបៀន ការបំភិតបំភ័យ ការចាប់ខ្លួនតាមទំនើងចិត្ត និងការផ្តន្ទាទោសដោយអយុត្តិធម៌ ចំពោះអ្នកនយោបាយពីគណបក្សប្រឆាំង អ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងសកម្មជនសិទ្ធិការងារ (ហ្វាំងឡង់)។

១៣៩.៧៩ ធានាថា ច្បាប់សន្តិសុខជាតិកំណត់ច្បាស់អំពីមូលដ្ឋានសម្រាប់ការរឹតត្បិតដែលអាចអនុញ្ញាតបាន ចំពោះសេរីភាពខាងការបញ្ចេញមតិ ដែលស្របតាមបទដ្ឋានអន្តរជាតិ រួមទាំង បទប្បញ្ញត្តិនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (លីទុយអានី)។

១៣៩.៨០ ធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលរឹតបន្តឹងហួសហេតុលើសេរីភាពខាងការបញ្ចេញមតិ ដោយធានាថាច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងនោះអនុលោមពេញលេញទៅតាមបទដ្ឋានសិទ្ធិមនុស្ស (អេស្តូនី)។

១៣៩.៨១ អនុម័តវិធានការចាំបាច់នានា សម្រាប់ការអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់អ្នកសារព័ត៌មាន និងប្រជាពលរដ្ឋទូទៅដោយសេរី ព្រមទាំងបញ្ឈប់ការផ្តន្ទាទោសពួកគេ ដោយពិចារណាលើអនុសាសន៍របស់អាហ្សង់ទីនកាលពីឆ្នាំ២០១៩ (អាហ្សង់ទីន)។

១៣៩.៨២ បង្កើនកិច្ចខិតខំប្រឹងប្រែងទ្វេដង ដើម្បីធានាការអនុវត្តសេរីភាពខាងការបញ្ចេញមតិ ដោយសេរី តាមរយៈការចាត់វិធានការដើម្បីការពារអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស (ស៊ីលី)។

១៣៩.៨៣ រៀបចំកិច្ចពិគ្រោះយោបល់ដែលមានអត្ថន័យ ជាមួយសង្គមស៊ីវិល ស្តីពី សេចក្តីព្រាងច្បាប់នានា ដែលមានផលប៉ះពាល់លើសេរីភាពខាងការបញ្ចេញមតិ រួមទាំង សេចក្តីព្រាងច្បាប់ ស្តីពីបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា សន្តិសុខប្រព័ន្ធបច្ចេកវិទ្យា និងការការពារទិន្នន័យផ្ទាល់ខ្លួន (ស៊ុយអែត)។

១៣៩.៨៤ ធានាថា សេចក្តីព្រាងច្បាប់ដែលកំពុងរង់ចាំការអនុម័ត ត្រូវបានកែសម្រួល មុនការអនុម័ត ដើម្បីឱ្យអនុលោមតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា រួមទាំងច្បាប់ស្តីពីបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា សន្តិសុខប្រព័ន្ធ
បច្ចេកវិទ្យា និងសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន (សហរដ្ឋអាមេរិក)។

១៣៩.៨៥ ស៊ើបអង្កេតរាល់សំណុំរឿងនៃអំពើហិង្សា លើអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស អ្នកការពារបរិស្ថាន សមាជិកសង្គមស៊ីវិល ថ្នាក់ដឹកនាំគណបក្សប្រឆាំង ដែលរងការវាយប្រហារ ការបៀតបៀន ឬការបំភិតបំភ័យ ចំពោះការប្រើប្រាស់សិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់ពួកគេ និងដោះលែងបុគ្គលទាំងអស់ដែលត្រូវបានឃុំខ្លួនដោយសារមូលដ្ឋាននេះ (បែលហ្ស៊ិក)។

១៣៩.៨៦ ធានាសេរីភាពខាងការបញ្ចេញមតិរបស់ពលរដ្ឋ និងអ្នកសារព័ត៌មាន តាមរយៈការកែសម្រួលក្រមព្រហ្មទណ្ឌរបស់កម្ពុជា (បារាំង)។

១៣៩.៨៧ លុប ឬធ្វើវិសោធនកម្មមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ និងនិរាករណ៍អនុក្រឹត្យ ឆ្នាំ២០២១ ស្តីពី ការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ និងនិរាករណ៍ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធានាលំហពលរដ្ឋពេញលេញ និងការពារសេរីភាពជាមូលដ្ឋាន របស់អ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន (ព្រះរាជាណាចក្រហូឡង់)។

១៣៩.៨៨ កែប្រែការសម្រេចបិទស្ថាប័នព័ត៌មានដោយបង្ខំ និងនិរាករណ៍បទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌដែលកំណត់ការបរិហារកេរ្តិ៍ ជាបទល្មើសព្រហ្មទណ្ឌ និងការរឹតបន្តឹងសេរីភាពខាងការបញ្ចេញមតិ និងការប្រមូលផ្តុំ (នូវែលសេឡង់)។

១៣៩.៨៩ ធានាសេរីភាពខាងការបញ្ចេញមតិ និងឯករាជ្យភាពនៃប្រព័ន្ធផ្សព្វផ្សាយ ជាពិសេស តាមរយៈការនិរាករណ៍មាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ

ធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន និងអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដែលស្របនឹងបទដ្ឋានអន្តរជាតិ (ស្វីស)។

១៣៩.៩០ ពង្រឹងការចូលរួមរបស់សង្គមស៊ីវិល និងសេរីភាពខាងការបញ្ចេញមតិ តាមរយៈការនិរាករណ៍សេចក្តីសម្រេចបិទគេហទំព័រប្រព័ន្ធផ្សព្វផ្សាយ និងរៀបចំកិច្ចពិគ្រោះយោបល់ ប្រកបដោយអត្ថន័យជាមួយសង្គមស៊ីវិលស្តីពីការផ្លាស់ប្តូរក្នុងច្បាប់ដែលត្រូវបានស្នើ (ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង)។

១៣៩.៩១ អនុវត្តរាល់កិច្ចខិតខំប្រឹងប្រែង ដើម្បីធានាថា យន្តការអចិន្ត្រៃយ៍សម្របសម្រួលព័ត៌មាន និងសាធារណមតិ ដែលគ្រោងនឹងបង្កើតឡើង នឹងមិនរឹតបន្តឹងចំពោះការទទួលបានព័ត៌មានប្រភេទផ្សេងៗ ដើម្បីប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃព័ត៌មានក្លែងក្លាយ (សាធារណរដ្ឋឆែក)។

១៣៩.៩២ បញ្ឈប់ ការជ្រៀតជ្រែក ការបិទខ្ទប់ ការបិទ និងការឈ្លបមើលតាមទំនើងចិត្ត លើប្រព័ន្ធផ្សព្វផ្សាយទាំងអនឡាញ និងបែបប្រពៃណី និងការប្រើប្រាស់ច្បាប់បែបគាបសង្កត់ និងការត្រួតពិនិត្យមាតិកា និងដើម្បីគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ (អេស្តូនី)។

១៣៩.៩៣ ចៀសវាងការអនុម័តច្បាប់បែបរឹតបន្តឹង ដែលតម្រូវឱ្យមានការចុះបញ្ជីអ្នកសារព័ត៌មានជាមួយក្រសួងព័ត៌មាន និងសេចក្តីព្រាងក្រមសីលធម៌ ដែលនឹងដាក់កំហិតលើមតិរិះគន់ និងសេរីភាពខាងការបញ្ចេញមតិ ការប្រមូលផ្តុំ និងការបង្កើតសមាគម (អេស្ប៉ាញ)។

១៣៩.៩៤ បង្កើតអាជ្ញាធរផ្សព្វផ្សាយឯករាជ្យ ដោយកំណត់វិធានច្បាស់លាស់ពាក់ព័ន្ធនឹងការផ្តល់ និងការលុបចោលអាជ្ញាបណ្ណផ្សព្វផ្សាយ (សំប៊ី)។

១៣៩.៩៥ លើកកម្ពស់វិធានការ ដើម្បីធានាសិទ្ធិក្នុងការធ្វើបាតុកម្មដោយសន្តិវិធី (កូឡុំប៊ី)។

១៣៩.៩៦ ធានាថា ការប្រើប្រាស់កម្លាំងអំឡុងពេលបាតុកម្មជាករណីលើកលែង ដោយអនុលោមយ៉ាងតឹងរ៉ឹងទៅនឹងគោលការណ៍ច្បាប់ ការប្រុងប្រយ័ត្នជាមុន ភាពចាំបាច់ សមាមាត្រ និងគណនេយ្យភាព និងផ្តល់ការបណ្តុះបណ្តាលអំពីសិទ្ធិមនុស្សគ្រប់ជ្រុងជ្រោយ និងជាប្រចាំ សម្រាប់មន្ត្រីអនុវត្តច្បាប់ ដែលទទួលខុសត្រូវចំពោះការយាមកាមក្នុងអំឡុងពេលការធ្វើបាតុកម្ម (កូស្តារីកា)។

១៣៩.៩៧ ធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីអនុលោមតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិ

នយោបាយ ដោយមានកិច្ចពិគ្រោះយោបល់មួយប្រកបដោយតម្លាភាព និងពិចារណាលើអនុសាសន៍របស់សង្គមស៊ីវិល (អៀរឡង់)។

១៣៩.៩៨ ពិនិត្យលើ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីព ឡើងវិញ ដើម្បីធានាសង្គតិភាពជាមួយកាតព្វកិច្ចរបស់រដ្ឋដូចមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ម៉ារ៉ុក)។

១៣៩.៩៩ ធ្វើឱ្យច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានអនុលោមភាពនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ដាណឺម៉ាក)។

១៣៩.១០០ អនុញ្ញាតឱ្យគណបក្សនយោបាយ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ សហជីពឯករាជ្យ និងសង្គមស៊ីវិលទាំងអស់ដំណើរការដោយសេរី និងធានានូវសិទ្ធិ និងសេរីភាពរបស់ពួកគេ ដូចបានការពារដោយរដ្ឋធម្មនុញ្ញ (កាណាដា)។

១៣៩.១០១ និរាករណ៍វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោត ដែលរឹតបន្តឹងខ្លាំងពេកចំពោះការចូលរួមនយោបាយ និងដាក់កំហិតចំពោះការអនុវត្តសេរីភាពខាងការបញ្ចេញមតិ ការប្រមូលផ្តុំដោយសន្តិវិធី និង សមាគម (សហរដ្ឋអាមេរិក)។

១៣៩.១០២ អនុញ្ញាតឱ្យមានការប្រកួតប្រជែងនយោបាយពិតប្រាកដ ពង្រីកលំហពលរដ្ឋ និងធានាការពារសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សមាគម និងការប្រមូលផ្តុំ (អូស្ត្រាលី)។

១៣៩.១០៣ ធានាការចូលរួមយ៉ាងពេញលេញ របស់គណបក្សប្រឆាំង និងសង្គមស៊ីវិលទាំងអស់ក្នុងជីវភាពនយោបាយ និងដោះលែងសកម្មជនគណបក្សប្រឆាំងដែលកំពុងត្រូវបានឃុំខ្លួន (បារាំង)។

១៣៩.១០៤ ចាត់វិធានការ ដើម្បីធានាការចូលរួមរបស់ពលរដ្ឋ ក្នុងជីវភាពនយោបាយ និងសាធារណៈ ដោយគ្មានការបំភិតបំភ័យ ជាពិសេស សំដៅដល់ការកម្រិតការប្រើពាក្យបណ្តឹងជាយុទ្ធសាស្ត្រ ប្រឆាំងនឹងការចូលរួមជាសាធារណៈ (អាល្លឺម៉ង់)។

១៣៩.១០៥ ស៊ើបអង្កេតឱ្យបានគ្រប់ជ្រុងជ្រោយ និងឯករាជ្យលើការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងការបៀតបៀន ការបំភិតបំភ័យ និងការឃុំខ្លួនតាមទំនើងចិត្ត និងអំពើហិង្សាមកលើសមាជិក និងអ្នកគាំទ្រគណបក្សប្រឆាំង (ប៉ារ៉ាហ្គាយ)។

១៣៩.១០៦ បើកចំហលំហនយោបាយ និងលំហពលរដ្ឋ និងផ្តល់សិទ្ធិបោះឆ្នោតឡើងវិញដល់គណបក្សនានា ស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ

របស់កម្ពុជា រួមទាំងការធានាក្នុងមាត្រា ២៥ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលពលរដ្ឋគ្រប់រូបមានសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈតាមរយៈអ្នកតំណាងដែលពួកគេបានជ្រើសរើសដោយសេរី (នូវែលសេឡង់)។

១៣៩.១០៧ ស្តារលំហពលរដ្ឋឡើងវិញ បង្កើតលក្ខខណ្ឌដើម្បីឱ្យមានប្រជាធិបតេយ្យសេរីពហុបក្សពិតប្រាកដ រួមទាំងការបោះឆ្នោតដោយសេរី និងយុត្តិធម៌ និងធានាប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (ន័រវេស)។

១៣៩.១០៨ ស្តារបរិយាកាសបរិសុទ្ធ ដោយសេរី និងបើកចំហឡើងវិញ ដើម្បីឱ្យអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់អាចប្រើប្រាស់សិទ្ធិបោះឆ្នោតរបស់ពួកគេដោយសេរី ហើយគណបក្សនយោបាយទាំងអស់អាចរៀបចំយុទ្ធនាការ និងចូលរួមក្នុងការបោះឆ្នោតដោយស្របច្បាប់ (ស្វីស)។

១៣៩.១០៩ ធានាលំហនយោបាយសេរី និងបើកចំហ ដែលអនុញ្ញាតឱ្យគណបក្សប្រឆាំងមានឱកាសស្មើគ្នាដើម្បីចូលរួមក្នុងការបោះឆ្នោត (ក្រូអាស៊ី)។

១៣៩.១១០ ចាត់វិធានការ ដើម្បីធានាសិទ្ធិរបស់អ្នកទាំងឡាយ ដែលធ្វើការងារដើម្បីការពារ និងលើកកម្ពស់សិទ្ធិមនុស្ស ជាពិសេស អ្នកការពារសិទ្ធិមនុស្ស ដោយអនុវត្តតាមអនុសាសន៍របស់អាហ្សង់ទីននៅឆ្នាំ២០១៩ (អាហ្សង់ទីន)។

១៣៩.១១១ ដោះលែងអ្នកទោសនយោបាយ អ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន បុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ និងអ្នកតស៊ូមតិដើម្បីសិទ្ធិមនុស្ស និងប្រជាធិបតេយ្យផ្សេងទៀត ជាបន្ទាន់ និងដោយឥតលក្ខខណ្ឌ និងទម្លាក់ចោលការចោទប្រកាន់ចំពោះពួកគេ រួមទាំងដោះលែងលោក កឹម សុខា មេដឹកនាំគណបក្សប្រឆាំង (នូវែលសេឡង់)។

១៣៩.១១២ ដោះលែងជាបន្ទាន់ និងដោយឥតលក្ខខណ្ឌ រាល់បុគ្គលទាំងឡាយ ដែលត្រូវបានដាក់ពន្ធនាគារដោយសារតែការប្រើប្រាស់ សិទ្ធិប្រមូលផ្តុំដោយសន្តិវិធី និងសមាគម របស់ខ្លួន (ដាណឺម៉ាក)។

១៣៩.១១៣ បញ្ឈប់ការបៀតបៀនតាមប្រព័ន្ធតុលាការចំពោះសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងដោះលែងអ្នកទាំងឡាយដែលត្រូវបានឃុំខ្លួនដោយអយុត្តិធម៌ ដោយសារការប្រើប្រាស់សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់ពួកគេ រួមទាំងលោក កឹម សុខា និងកញ្ញា សេង ធារី (សហរដ្ឋអាមេរិក)។

១៣៩.១១៤ រៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយការពារសុវត្ថិភាព ដែលមានតម្លាភាព ដើម្បីការពារសិទ្ធិទទួលបានឯកជនភាព និងធានាសុវត្ថិភាពក្នុងបរិយាកាសឌីជីថល ជាពិសេស សម្រាប់កុមារ (លិចតិនស្តាញ)។

១៣៩.១១៥ ពិចារណាសិទ្ធិទទួលបានឯកជនភាព ក្នុងសេចក្តីព្រាងច្បាប់ ស្តីពី អ៊ីនធឺណិត លំហបច្ចេកវិទ្យា និងបរិយាកាសឌីជីថល (ប្រេស៊ីល)។

១៣៨.១១៦ កែសម្រួលមាត្រា ២១ ២២ ៩៤៨ និង មាត្រា៩៥៣ នៃក្រមរដ្ឋប្បវេណី ដើម្បីកំណត់អាយុអប្បបរមា សម្រាប់ការរៀបអាពាហ៍ពិពាហ៍នៅអាយុ ១៨ឆ្នាំ ដោយគ្មានការលើកលែង ហាមឃាត់អាពាហ៍ពិពាហ៍កុមារ និងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍បែបនេះ (ម៉ិកស៊ិក)។

១៣៩.១១៧ អនុម័តវិធានការច្បាប់ និងរៀបចំយុទ្ធនាការលើកកម្ពស់ការយល់ដឹង ក្នុងគោលបំណងហាមឃាត់អាពាហ៍ពិពាហ៍កុមារ (ស៊ីលី)។

១៣៩.១១៨ អនុម័តវិធានការបែបផ្តោតគោលដៅ រួមទាំងកម្មវិធីលើកកម្ពស់ការយល់ដឹង ស្តីពី ឥទ្ធិពលគ្រោះថ្នាក់នៃអាពាហ៍ពិពាហ៍កុមារលើសុខភាព ការអភិវឌ្ឍ និងការអប់រំរបស់កុមារី (ស៊ីប)។

១៣៩.១១៩ រៀបចំផែនការសកម្មភាពជាតិ ដើម្បីទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះវ័យជំទង់ និងធានាថាកុមារីអាចចូលរួមក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាពនេះ (ប៉ាណាម៉ា)។

១៣៩.១២០ រៀបចំផែនការសកម្មភាពជាតិ ដើម្បីទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះវ័យជំទង់ និងវិភាជធនធានសមស្របសម្រាប់ការអនុវត្តន៍ផែនការសកម្មភាពនេះ (បែលហ្ស៊ិក)។

១៣៩.១២១ បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេស ការជួញដូរស្ត្រី និងកុមារ និងប្រយុទ្ធប្រឆាំងពលកម្មដោយបង្ខំ និងការកេងប្រវ័ញ្ចផ្លូវភេទ (អ៊ីតាលី)។

១៣៩.១២២ បង្កើនកិច្ចខិតខំប្រឹងប្រែង ក្នុងការលុបបំបាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់ និងការកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និងកុមារ ដែលជាលទ្ធផលនៃការជួញដូរ (លីបង់)។

១៣៩.១២៣ បន្តចាត់វាល់វិធានការ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ម៉ាឡាវី)។

១៣៩.១២៤ ពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ ស៊ើបអង្កេត និងផ្តន្ទាទោសសំណុំរឿងជួញដូរមនុស្ស ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម ជាពិសេស នៅតាមទីតាំងឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងធានាកិច្ចការពារគ្រប់គ្រាន់ និងសំណងពេញលេញចំពោះជនរងគ្រោះ ការដោះស្រាយតាមតម្រូវការជាក់លាក់របស់ស្ត្រី និងកុមារី (ម៉ិកស៊ិក)។

១៣៩.១២៥ បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយការជួញដូរមនុស្ស (អ៊ីរ៉ាក់)។

១៣៩.១២៦ ពង្រឹងកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រួមទាំងកិច្ចការពារជនរងគ្រោះនៃអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ស្រីលង្កា)។

១៣៩.១២៧ ពង្រឹងច្បាប់ និងបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបន្ថែមទៀត ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រួមទាំង ការជួញដូរស្ត្រី និងកុមារ និងអ្នកទាំងឡាយដែលស្ថិតក្នុងស្ថានភាពពលកម្មដោយបង្ខំ តាមរយៈការចាត់វិធានការការពារជនរងគ្រោះ និងវិធានការទប់ស្កាត់ (ម៉ុងហ្គោលី)។

១៣៩.១២៨ ធានាការអនុវត្តច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រកបដោយប្រសិទ្ធភាព (ម៉ុងតេណេហ្គ្រោ)។

១៣៩.១២៩ ធានាការអនុវត្តច្បាប់ក្នុងការបង្ក្រាបអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ប្រកបដោយប្រសិទ្ធភាព (ប៉ារ៉ាហ្គាយ)។

១៣៩.១៣០ បង្កើនការរៀបចំយុទ្ធនាការ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ក្នុងគោលបំណងពលកម្មដោយបង្ខំ និងការកេងប្រវ័ញ្ចផ្លូវភេទ ជាពិសេសលើស្ត្រីនិងកុមារី (ហ្វីលីពីន)។

១៣៩.១៣១ បន្តចាត់វិធានការចាំបាច់ទាំងអស់ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (សាធារណរដ្ឋកូរ៉េ)។

១៣៩.១៣២ បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (អារ៉ាប៊ីសាអូឌីត)។

១៣៩.១៣៣ អភិវឌ្ឍវិធានការនានា សំដៅកាត់បន្ថយករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ជាពិសេស ដោយសារការរាយការណ៍ជាច្រើន អំពីករណីដែលមានបុគ្គលរងការបង្ខំឱ្យធ្វើការ ក្នុងមណ្ឌលទំនាក់ទំនងតាមទូរសព្ទ ដែលភាគច្រើនតែងមានអំពើហិង្សា (អេស្ប៉ាញ)។

១៣៩.១៣៤ បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រួមទាំង ករណីពាក់ព័ន្ធប្រតិបត្តិការឆបោកតាមប្រព័ន្ធអនឡាញ តាមរយៈការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព និងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ (ថៃ)។

១៣៩.១៣៥ ស៊ើបអង្កេត និងផ្តន្ទាទោសជនល្មើសនៃអំពើជួញដូរមនុស្ស និងមន្ត្រីដែលសមគំនិតក្នុងពលកម្មដោយបង្ខំ និងប្រតិបត្តិការឆបោកតាមប្រព័ន្ធអនឡាញ និងផ្តល់ការគាំទ្រដល់ជនរងគ្រោះ (សហរដ្ឋអាមេរិក)។

១៣៩.១៣៦ បន្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ព្រមទាំងយុទ្ធនាការលើកកម្ពស់ការយល់ដឹង និងយុទ្ធនាការទប់ស្កាត់ ប្រកបដោយជោគជ័យ (វ៉េណេស៊ុយអេឡា)។

១៣៩.១៣៧ អនុម័តវិធានការនានា ដើម្បីប្រយុទ្ធប្រឆាំង និងទប់ស្កាត់ពលកម្មកុមារ និងអំពើជួញដូរកុមារ និងផ្តន្ទាទោសជនល្មើសនៃការរំលោភបំពានបែបនេះ (អាហ្សង់ទីន)។

១៣៩.១៣៨ ចាត់វិធានការបន្ថែមទៀត ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០១៩ - ២០២៣) (បង់ក្លាដែស)។

១៣៩.១៣៩ បន្តអនុវត្តវិធានការ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការពារជនរងគ្រោះ រួមទាំងតាមរយៈការពង្រឹងសមត្ថភាពរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (បេឡារុស)។

១៣៩.១៤០ បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈការអនុវត្តច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រកបដោយប្រសិទ្ធភាព (ប៊ូតង់)។

១៣៩.១៤១ អនុម័តវិធានការដើម្បីពង្រឹងការអនុវត្តច្បាប់ ស្តីពី អំពើជួញដូរមនុស្ស និងរៀបចំ ព្រមទាំងអនុវត្តពិធីសារសម្រាប់ការសង្គ្រោះ និងកិច្ចការពារជនរងគ្រោះ ដោយសហការជាមួយអង្គការអន្តរជាតិ និងប្រទេសដែលរងផលប៉ះពាល់ (ប្រេស៊ីល)។

១៣៩.១៤២ ធានាការអនុវត្តច្បាប់ក្នុងស្រុកដែលចូលជាធរមាន ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ប្រកបដោយប្រសិទ្ធភាព និងផ្តល់កិច្ចការពារគ្រប់គ្រាន់សម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ (ប៊ុលហ្គារី)។

១៣៩.១៤៣ បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការលុបបំបាត់អំពើជួញដូរមនុស្សទាំងស្រុង ជាពិសេស អំពើជួញដូរកុមារ (បួគីណាហ្វាសូ)។

១៣៩.១៤៤ ចាត់វិធានការ ដើម្បីដោះស្រាយអំពើជួញដូរមនុស្ស ផ្តល់សេវាផ្នែកច្បាប់ មាតុភូមិនិវត្តន៍ និងស្តារនីតិសម្បទាដល់ជនរងគ្រោះ (ស៊ីលី)។

១៣៩.១៤៥ ពង្រឹងកិច្ចខិតខំប្រឹងប្រែងគួរឱ្យកត់សម្គាល់ ក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេស ការជួញដូរស្ត្រី និងកុមារ (ក្រូអាស៊ី)។

១៣៩.១៤៦ បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈការពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធយ៉ាងហ្មត់ចត់ (ឥណ្ឌូនេស៊ី)។

១៣៩.១៤៧ ពង្រឹងយន្តការទប់ស្កាត់ និងការទទួលបានយុត្តិធម៌ ក្នុងការប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ (ហ្វីលីពីន)។

១៣៩.១៤៨ ពង្រឹងកិច្ចការពារផ្លូវច្បាប់សម្រាប់កុមារ ប្រឆាំងនឹងពលកម្មកុមារ (ស្រីលង្កា)។

១៣៩.៤៩ បន្តវិធានការចាំបាច់ ដើម្បីអនុវត្តផែនការសកម្មភាពជាតិ ដើម្បីកាត់បន្ថយពលកម្មកុមារ (អារ៉ាប៊ីសាអូឌីត)។

១៣៩.១៥០ បន្តពង្រឹងកិច្ចខិតខំប្រឹងប្រែង និងគោលនយោបាយរបស់ខ្លួនក្នុងការបង្កើនលទ្ធភាពទទួលបានការងារ ជាពិសេស សម្រាប់យុវជន ស្ត្រី ជនមានពិការភាព និងប្រជាជនរស់នៅតាមទីជនបទ (វៀតណាម)។

១៣៩.១៥១ ការពារសិទ្ធិរបស់ពលករទាំងអស់ ទាំងវិស័យក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ និងធានាថា ពួកគេទទួលបានកិច្ចគាំពារសង្គមគ្រប់គ្រាន់ និងប្រាក់ឈ្នួលសមរម្យ និងចាត់វិធានការបង្ក្រាប ប្រកបដោយប្រសិទ្ធភាពប្រឆាំងនឹងអំពើជួញដូរកុមារ និងពលកម្មកុមារ (លុចសំបួ)។

១៣៩.១៥២ ធ្វើឱ្យលក្ខខណ្ឌការងារមានភាពប្រសើរឡើង (អ៊ីរ៉ាក់)។

១៣៩.១៥៣ បន្តកិច្ចខិតខំប្រឹងប្រែង ក្នុងការការពារសិទ្ធិការងារ ជាពិសេសក្នុងឧស្សាហកម្មកាត់ដេរ ដែលកម្មករភាគច្រើនធ្វើការក្នុងវិស័យនេះ (បារ៉ែន)។

១៣៩.១៥៤ ធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីព ដោយពិគ្រោះយោបល់ជាមួយកម្មករ សហជីព និងភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីធ្វើឱ្យមានអនុលោមភាពពេញលេញតាមអនុសញ្ញាលេខ៨៧ ស្តីពី សេរីភាពនៃសមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគម (១៩៤៨) និង អនុសញ្ញាលេខ ៩៨ ស្តីពី សិទ្ធិបង្កើតសមាគម និងសិទ្ធិនៃការចរចាជាសមូហភាព (១៩៤៩) របស់ ILO (បែលហ្ស៊ិក)។

១៣៩.១៥៥ ធ្វើឱ្យការចុះបញ្ជីសហជីពមានភាពងាយស្រួល និងកាត់បន្ថយលិខិតបទដ្ឋានគតិយុត្ត ដែលដាក់កំហិតលើសិទ្ធិប្រមូលផ្តុំដោយសន្តិវិធី និងសិទ្ធិធ្វើកូដកម្ម ព្រមទាំងពង្រឹងកិច្ចការពារអ្នកដឹកនាំសហជីព និងកម្មករ (អាល្លឺម៉ង់)។

១៣៩.១៥៦ បង្កើនកិច្ចខិតខំប្រឹងប្រែង ក្នុងការបង្កើតប្រព័ន្ធសន្តិសុខសង្គមគ្រប់ជ្រុងជ្រោយ ដែលមានការគ្របដណ្តប់ជាសកលសម្រាប់ទាំងអស់គ្នា (ម៉ាល់ឌីវ)។

១៣៩.១៥៧ ខិតខំប្រឹងប្រែងក្នុងការបង្កើតប្រព័ន្ធសន្តិសុខសង្គម ដែលអាចផ្តល់អភិបាលកិច្ចជាសកល និងដោយគ្មានការរើសអើង (អាល់ហ្សេរី)។

១៣៩.១៥៨ បន្តការងារកាត់បន្ថយភាពក្រីក្រ ដើម្បីបង្កើនកម្រិតជីវភាពរស់នៅ បន្ថែមទៀត និងផ្តល់ផលប្រយោជន៍កាន់តែច្រើនចំពោះប្រជាជនក្នុងប្រទេស(ចិន)។

១៣៩.១៥៩ បន្តវិធានការកាត់បន្ថយភាពក្រីក្រ ដើម្បីកែលម្អគុណភាពជីវិតរបស់ប្រជាពលរដ្ឋទូទាំងប្រទេស រួមទាំងនៅតាមតំបន់ជនបទ (បូលីវី)។

១៣៩.១៦០ បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការសម្រេចបានកំណើនសេដ្ឋកិច្ច ដែលមានបំណងបង្កើនកម្រិតជីវភាពរស់នៅរបស់ប្រជាជនទាំងអស់ រួមទាំងប្រជាជនរស់នៅតាមតំបន់ដាច់ស្រយាល (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ)។

១៣៩.១៦១ បន្តវិនិយោគលើកម្មវិធីកាត់បន្ថយភាពភាពក្រីក្រ អភិវឌ្ឍជនបទ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបង្កើនកម្រិតជីវភាពរស់នៅ និងលើកកម្ពស់កំណើនសេដ្ឋកិច្ចក្នុងប្រទេសប្រកបដោយបរិយាបន្ន (ម៉ាឡេស៊ី)។

១៣៩.១៦២ បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយភាពក្រីក្រ និងបង្កើនកម្រិតជីវភាពរស់នៅក្នុងប្រទេស (វ៉េណេស៊ុយអេឡា)។

១៣៩.១៦៣ បន្តការងារឆ្ពោះទៅរកការធានាបន្ថែមទៀត នូវសិទ្ធិសេដ្ឋកិច្ចសង្គមរបស់ពលរដ្ឋ និងពង្រឹងលទ្ធភាពរបស់ពលរដ្ឋក្នុងការទទួលបានការថែទាំសុខភាព និងការអប់រំ (រុស្ស៊ី)។

១៣៩.១៦៤ ពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម រួមទាំងតាមរយៈការបង្កើតឱកាសសេដ្ឋកិច្ចកាន់តែច្រើន ការពង្រឹងសេវាចាំបាច់ ដូចជា ការថែទាំសុខភាព និងការអប់រំ និងបង្កើនការចូលរួមក្នុងកម្មវិធីកសាងសមត្ថភាព ដែលផ្តល់ដោយរដ្ឋសមាជិកនានា សហគមន៍ថ្នាក់តំបន់ និងអន្តរជាតិ (ម៉ាឡេស៊ី)។

១៣៩.១៦៥ បន្តកិច្ចខិតខំប្រឹងប្រែងជាតិ ក្នុងគោលបំណងប្រយុទ្ធប្រឆាំងភាពក្រីក្រ និងផ្តល់កិច្ចគាំពារសង្គម (អេហ្ស៊ីប)។

១៣៩.១៦៦ បន្តបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយភាពក្រីក្រ និងការបង្កើនកម្រិតជីវភាពរស់នៅរបស់ប្រជាជន (អេត្យូពី)។

១៣៩.១៦៧ បន្តកិច្ចខិតខំប្រឹងប្រែងដ៏មានតម្លៃ ក្នុងការផ្គត់ផ្គង់ទឹកដែលមានសុវត្ថិភាព និងតម្លៃសមរម្យ ដើម្បីសម្រេចបានទាំងស្រុងនូវទស្សនវិស័យផែនការយុទ្ធសាស្ត្រជាតិ ស្ដីពី វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ (សាធារណរដ្ឋឥស្លាមអ៊ីរ៉ង់)។

១៣៩.១៦៨ បន្តពង្រឹងការគ្រប់គ្រងរួមលើធនធានទឹក ដើម្បីការពារសិទ្ធិទទួលបានទឹកទទួលទានដែលមានសុវត្ថិភាពសម្រាប់ប្រជាជនគ្រប់រូប (ចិន)។

១៣៩.១៦៩ ពន្លឿនដំណើរការរៀបចំការចុះបញ្ជីដី ដើម្បីពង្រឹងសន្តិសុខផ្នែកច្បាប់ នៃលិខិតបទដ្ឋានគតិយុត្ត និងសិទ្ធិ ពាក់ព័ន្ធនឹងអចលនទ្រព្យ ជាលទ្ធផលនឹងចូលរួមបង្ការភាពទោមនស្សក្នុងសង្គម និងធានាសិទ្ធិទទួលបានជីវភាពរស់នៅសមរម្យ (សាធារណរដ្ឋឆែក)។

១៣៩.១៧០ អនុវត្តយន្តការកិច្ចការពារប្រកបដោយគណនេយ្យភាព និងតម្លាភាព ដើម្បីបង្ការ និងតវ៉ាចំពោះការបណ្ដេញចេញពីដីដោយខុសច្បាប់ និងការប្រើប្រាស់ដីដែលត្រូវបានការពារក្នុងបរិបទបរិស្ថានដោយខុសច្បាប់ (កាណាដា)។

១៣៩.១៧១ បង្កើតយន្តការឯករាជ្យមួយ ដើម្បីដោះស្រាយវិវាទដីធ្លី ដែលមានភាពយុត្តិធម៌ ការចូលរួម និងតម្លាភាព (បារាំង)។

១៣៩.១៧២ បន្តការប្ដេជ្ញាចិត្ត ចំពោះការសម្រេចបានសេវាសុខភាពដែលមានការគ្របដណ្ដប់ជាសកល សម្រាប់ប្រជាជន (ស៊ែប៊ី)។

១៣៩.១៧៣ ពង្រឹងប្រព័ន្ធថែទាំសុខភាព ក្នុងគោលបំណងលើកកម្ពស់សេវាសុខភាពដែលមានការគ្របដណ្ដប់ជាសកល ទន្ទឹមនឹងនោះធានាថាមានការបញ្ចូលក្រុមបុគ្គលដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះដែរ (ថៃ)។

១៣៩.១៧៤ បន្តកិច្ចខិតខំប្រឹងប្រែង ក្នុងការពង្រីកការទទួលបានសេវាថែទាំសុខភាព និងប្រព័ន្ធធានារ៉ាប់រងសុខភាព ដោយផ្ដោតលើគោលដៅនៃសេវាសុខភាពដែលមានការគ្របដណ្ដប់ជាសកល (វៀតណាម)។

១៣៩.១៧៥ ពង្រឹងការទទួលបានសេវាសុខភាពប្រកបដោយគុណភាព ជាពិសេស នៅតំបន់ជនបទ និងសម្រាប់កុមារមានពិការភាព កុមារមកពីក្រុមជនជាតិភាគតិច និងកុមារចំណាកស្រុក និងធានាថា មណ្ឌលសុខាភិបាលទាំងអស់មាន
សម្ភារៈ បរិក្ខារ ទឹកស្អាត អនាម័យ និងអនាម័យខ្លួនប្រាណគ្រប់គ្រាន់ (ប៉ូឡូញ)។

១៣៩.១៧៦ បន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រឹងការទទួលបានសេវាសុខភាពប្រកបដោយគុណភាព និងពិចារណាលើវិធីនានា ដើម្បីពង្រីកការគ្របដណ្ដប់នៃសេវាសុខភាព (សាធារណរដ្ឋអារ៉ាប់ស៊ីរី)។

១៣៩.១៧៧ ចាត់អាទិភាពលើវិធានការនានា ដើម្បីពង្រឹងការទទួលបានសេវាសុខភាពប្រកបដោយគុណភាព ជាពិសេស នៅតំបន់ជនបទ និងសម្រាប់កុមារមានពិការភាព កុមារមកពីក្រុមជនជាតិភាគតិច និងកុមារចំណាកស្រុក (អ៊ុយក្រែន)។

១៣៩.១៧៨ បន្តកិច្ចខិតខំប្រឹងប្រែង ក្នុងការពង្រឹងការអនុវត្តគោលនយោបាយស្តីពីសុខភាពសាធារណៈ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធថែទាំសុខភាពនៅតំបន់ដាច់ស្រយាល (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ)។

១៣៩.១៧៩ អនុវត្តវិធានការ ដើម្បីបង្កើនសមត្ថភាពថែទាំ ក្នុងសេវាសុខភាពជាតិ (សាធារណរដ្ឋដូមីនីក)។

១៣៩.១៨០ បន្តកិច្ចខិតខំប្រឹងប្រែង ឆ្ពោះទៅពង្រឹងការទទួលបានការថែទាំសុខភាពដែលមានតម្លៃសមរម្យ និងប្រកបដោយគុណភាព ជាពិសេស សម្រាប់ប្រជាជនក្រីក្រ និងក្រុមដែលងាយរងគ្រោះ (ឥណ្ឌា)។

១៣៩.១៨១ ពង្រឹងការទទួលបានការថែទាំសុខភាព និងការអប់រំប្រកបដោយគុណភាព ជាពិសេស នៅតំបន់ជនបទ និងក្នុងចំណោមក្រុមងាយរងគ្រោះ តាមរយៈ ការកាត់បន្ថយឧបសគ្គផ្នែកហិរញ្ញវត្ថុចំពោះការអប់រំ និងពង្រឹងសម្ភារៈបរិក្ខារថែទាំសុខភាព (ឥណ្ឌូនេស៊ី)។

១៣៩.១៨២ ពង្រឹងបន្ថែមទៀត ចំពោះវិធានការនានាក្នុងការពង្រឹងសេវាថែទាំសុខភាព ជាពិសេស ការវិភាជធនធានកាន់តែច្រើន សម្រាប់ផែនការយុទ្ធសាស្ត្រជាតិ ដើម្បីបញ្ចប់ជំងឺរបេងនៅកម្ពុជា ២០២១-២០៣០ (ប៉ាគីស្ថាន)។

១៣៩.១៨៣ បន្តលើកិច្ចខិតខំប្រឹងប្រែងដែលមានស្រាប់ ដើម្បីពង្រឹងហេដ្ឋារចនាសម្ព័ន្ធសុខភាពសាធារណៈ ជាពិសេស ការពង្រឹងសេវាថែទាំសុខភាពមាតា សម្រាប់ស្ត្រី និងទារក (សិង្ហបុរី)។

១៣៩.១៨៤ បន្តពង្រឹងការទទួលបានសេវាសុខភាព ប្រកបដោយគុណភាព សម្ភារៈបរិក្ខារទឹកស្អាត អនាម័យ និងអនាម័យខ្លួនប្រាណ ជាពិសេស នៅតំបន់ជនបទ (ស៊ីមបាវ៉េ)។

១៣៩.១៨៥ ពង្រឹង កែលម្អ និងសម្របសម្រួលបន្ថែមទៀតចំពោះសកម្មភាពពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្ត (ព្រុយណេ)។

១៣៩.១៨៦ ធានាលទ្ធភាពជាសកល ក្នុងការទទួលព័ត៌មានអំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ តាមរយៈការពង្រីកកម្មវិធីអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយនៅសាលារៀន (អេស្តូនី)។

១៣៩.១៨៧ ធានាលទ្ធភាពទទួលបាន និងការមានសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជសមស្រប និងគុណភាពល្អ (អ៊ីស្លង់)។

១៣៩.១៨៨ ធានាលទ្ធភាពជាសកលក្នុងការទទួលបានព័ត៌មាន អំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ តាមរយៈការពង្រីក ការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ នៅសាលារៀន កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីកន្លែងនានានៅក្រៅសាលារៀន (អ៊ីស្លង់)។

១៣៩.១៨៩ បង្កើនលទ្ធភាពទទួលបានសេវាសុខភាព និងសេវាសង្គមកិច្ចសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន រួមទាំងអំពីការបង្ការ ព័ត៌មាន ការកាត់បន្ថយភាពឈឺចាប់ និងការព្យាបាល ដែលទទួលដោយស្ម័គ្រចិត្ត ងាយទទួលបានសម្រាប់មនុស្សគ្រប់រូប គ្មានការរើសអើង និងមានគុណភាពល្អ (ប៉ាណាម៉ា)។

១៣៩.១៩០ បន្តអនុវត្តអភិក្រមគ្រប់ជ្រុងជ្រោយ ដើម្បីធានាថា ពលរដ្ឋរបស់ខ្លួនបន្តទទួលបានការការពារពីបញ្ហាគ្រឿងញៀនពិភពលោក (សិង្ហបុរី)។

១៣៩.១៩១ បន្តកិច្ចខិតខំប្រឹងប្រែង ក្នុងការលើកកម្ពស់ការអប់រំ ដែលអាចស្វែងរកបាន មានតម្លៃសមរម្យ និងគុណភាព (ម៉ូរីស)។

១៣៩.១៩២ ពង្រឹងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនគុណភាពនៃការអប់រំ និងលទ្ធភាពទទួលបានការអប់រំសម្រាប់មនុស្សគ្រប់រូប (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ)។

១៣៩.១៩៣ បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងគុណភាពនៃប្រព័ន្ធអប់រំជាតិ និងផ្តល់លទ្ធភាពទទួលបានការអប់រំសម្រាប់មនុស្សគ្រប់រូប (សាធារណរដ្ឋអារ៉ាប់ស៊ីរី)។

១៣៩.១៩៤ ពិចារណាពង្រីកលទ្ធភាពទទួលបានការអប់រំ សម្រាប់ពលរដ្ឋគ្រប់រូប ទាំងពលរដ្ឋកម្ពុជា និងអ្នកមិនមែនពលរដ្ឋកម្ពុជា (ទីម័រខាងកើត)។

១៣៩.១៩៥ បន្តកិច្ចខិតខំប្រឹងប្រែង ក្នុងការបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់ធានាលទ្ធភាពទទួលបានការអប់រំដោយឥតគិតថ្លៃ និងប្រកបដោយគុណភាពសម្រាប់កុមារគ្រប់រូប (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ)។

១៣៩.១៩៦ បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងគុណភាពអប់រំ និងសម្របសម្រួលការទទួលបានការអប់រំ សម្រាប់មនុស្សគ្រប់រូប តាមរយៈការពង្រីកសេវាអប់រំទៅដល់កុមារ និងយុវជនគ្រប់រូបដោយស្មើភាព (សាធារណរដ្ឋដូមីនីក)។

១៣៩.១៩៧ បន្តកិច្ចខិតខំប្រឹងប្រែង ក្នុងការពង្រឹងគុណភាពអប់រំគ្រប់កម្រិតជាពិសេស នៅតំបន់ជនបទ រួមទាំងធានាថាការចូលរៀនថ្នាក់បឋមសិក្សាគឺជា

កាតព្វកិច្ច សម្រាប់កុមារគ្រប់រូប និងផ្តោតលើលទ្ធភាពទទួលបានការអប់រំប្រកប ដោយសមធម៌ និងបរិយាបន្ន (ឥណ្ឌា)។

១៣៩.១៩៨ បន្តកិច្ចខិតខំប្រឹងប្រែងក្នុងកំណែទម្រង់សេវាអប់រំសាធារណៈ របស់ខ្លួន និងធ្វើឱ្យការអប់រំថ្នាក់បឋមសិក្សាជាកាតព្វកិច្ច ហើយកុមារគ្រប់រូប អាចទទួលបានការអប់រំនេះ (តួកគី)។

១៣៩.១៩៩ បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការចាត់អាទិភាពលើការអប់រំ ពង្រឹងគុណភាពនៃការបង្រៀន និងបង្កើនហេដ្ឋារចនាសម្ព័ន្ធ ដើម្បីធានាការអប់រំ ប្រកបដោយបរិយាបន្ន និងគុណភាព សម្រាប់មនុស្សគ្រប់រូប (បង់ក្លាដែស)។

១៣៩.២០០ បន្តកិច្ចខិតខំប្រឹងប្រែង ក្នុងការពង្រឹងមុខងារនៃប្រព័ន្ធអប់រំជាតិ ដើម្បីផ្តល់ការអប់រំប្រកបដោយគុណភាព និងបរិយាបន្នសម្រាប់កុមារគ្រប់រូប និងបង្កើនការចុះឈ្មោះចូលរៀន និងអត្រាបញ្ចប់ការសិក្សា ព្រមទាំងកាត់បន្ថយ អត្រាបោះបង់ការសិក្សា នៅថ្នាក់មធ្យមសិក្សា (ប៊ុលហ្គារី)។

១៣៩.២០១ ពង្រឹងគំនិតផ្តួចផ្តើមនានាពាក់ព័ន្ធ នឹងការកែលម្អប្រព័ន្ធអប់រំជាតិ (ហ្សកហ្ស៊ី)។

១៣៩.២០២ បន្តបង្កើនកិច្ចខិតខំប្រឹងប្រែង ក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាព ជាពិសេស គោលដៅនានាពាក់ព័ន្ធនឹងគុណភាព និងលទ្ធ ភាពទទួលបានការអប់រំ (ព្រុយណេ)។

១៣៩.២០៣ បន្តការងារ ដើម្បីធ្វើឱ្យវិស័យអប់រំកាន់តែមានបរិយាបន្ន ជា ពិសេស សម្រាប់កុមារមានពិការភាព ស្របពេលជាមួយគ្នានោះ ប្រយុទ្ធប្រឆាំង បាតុភាពនៃការបោះបង់ការសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាព (លីបង់)។

១៣៩.២០៤ បន្តអនុវត្តវិធានការនានា ដើម្បីផ្តល់ការអប់រំប្រកបដោយបរិយាប ន្នដល់កុមារមានពិការភាពក្នុងសាលារៀននានា ដោយមានការគាំទ្រចាំបាច់ពី អ្នកជំនាញ (ម៉ាល់ឌីវ)។

១៣៩.២០៥ បន្តកិច្ចខិតខំប្រឹងប្រែង ក្នុងការពង្រឹងគុណភាពអប់រំគ្រប់កម្រិត ជាពិសេស នៅទីជនបទ និងធានាការទទួលបានការអប់រំប្រកបដោយបរិយាបន្ន សម្រាប់កុមារគ្រប់រូប រួមទាំងកុមារមានពិការភាព (សាធារណរដ្ឋកូរ៉េ)។

១៣៩.២០៦ ចាត់វិធានការច្បាស់លាស់ ដើម្បីលុបបំបាត់ឧបសគ្គជាក់លាក់ ដែលរារាំងកុមារីពីការចុះឈ្មោះចូលរៀន និងបន្តការសិក្សាថ្នាក់មធ្យម និងឧត្តម សិក្សា រួមមានភាពក្រីក្រ ឥរិយាបថចិញ្ចឹមកូនអវិជ្ជមាន ពិការភាព អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះវ័យជំទង់ (ព័រទុយហ្គាល់)។

១៣៩.២០៧ អនុវត្តវិធានការនានា ដើម្បីលុបបំបាត់ឧបសគ្គដែលកុមារីប្រឈមទាក់ទងនឹងការចុះឈ្មោះចូលរៀន និងបន្តការសិក្សានៅថ្នាក់មធ្យម និងឧត្តមសិក្សា ព្រមទាំងចាត់វិធានការដើម្បីដោះស្រាយផ្នត់គំនិតរើសអើងលើស្ត្រី និងកុមារី (ស៊ីមបាវ៉េ)។

១៣៩.២០៨ ចាត់វិធានការច្បាស់លាស់ ដើម្បីលុបបំបាត់ឧបសគ្គ ដែលកុមារីប្រឈមទាក់ទងនឹងការចុះឈ្មោះចូលរៀន និងបន្តការសិក្សា (ស៊ីប)។

១៣៩.២០៩ ពង្រឹងកិច្ចខិតខំប្រឹងប្រែងផ្ទៃក្នុង ដើម្បីធានាកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ពីការប្រែប្រួលអាកាសធាតុលើការគោរពសិទ្ធិមនុស្ស ជាពិសេសសម្រាប់មនុស្សចាស់ និងជនមានពិការភាព (សាធារណរដ្ឋឥស្លាមអ៊ីរ៉ង់)។

១៣៩.២១០ អនុម័តសកម្មភាពដែលទទួលខុសត្រូវ មិនប៉ះពាល់ដល់បរិស្ថាន ដើម្បីបង្កើតគោលនយោបាយដែលមានផលជះ ដើម្បីកាត់បន្ថយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ (វ៉ានូទូ)។

១៣៩.២១១ បញ្ចូលសិទ្ធិមនុស្សស្តីពីការទទួលបានបរិស្ថានស្អាត សុខភាពល្អ និងប្រកបដោយចីរភាព ទៅក្នុងច្បាប់ជាតិ និងកាន់តែប្រសើរ ក្នុងកម្រិតរដ្ឋធម្មនុញ្ញ (កូស្តារីកា)។

១៣៩.២១២ បន្តកិច្ចខិតខំប្រឹងប្រែងមុនៗ ឆ្ពោះទៅរកការអភិវឌ្ឍ ជាពិសេសដើម្បីកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ (សាធារណរដ្ឋឥស្លាមអ៊ីរ៉ង់)។

១៣៩.២១៣ អនុវត្តយុទ្ធសាស្ត្របញ្ចកោណប្រកបដោយប្រសិទ្ធភាព ផ្តោតលើកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព (កៀហ្ស៊ីស៊ីស្ថាន)។

១៣៩.២១៤ បន្តពង្រឹងស្ថាប័នរដ្ឋ ការសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងសមធម៌ សម្រាប់ប្រជាពលរដ្ឋកម្ពុជា (តង់សានី)។

១៣៩.២១៥ ចាត់វិធានការ ដើម្បីដោះស្រាយហានិភ័យចំពោះសិទ្ធិមនុស្សក្នុងបរិបទនៃសកម្មភាពធុរកិច្ច រួមទាំង ធ្វើឱ្យលក្ខខណ្ឌការងារ និងបទដ្ឋានការងារប្រសើរឡើង ព្រមទាំងក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ជប៉ុន)។

១៣៩.២១៦ បន្តផ្តោតការវិនិយោគលើសមភាពយេនឌ័រ កិច្ចការពារសិទ្ធិស្ត្រី យន្តការគណនេយ្យភាព និងការពង្រឹងអំណាចសេដ្ឋកិច្ច (កៀហ្ស៊ីស៊ីស្ថាន)។

១៣៩.២១៧ បន្តអនុវត្តយុទ្ធសាស្ត្រជាតិស្តីពី កំណើន ការងារ សមភាព និងប្រសិទ្ធភាព ដើម្បីពង្រឹងតួនាទីរបស់ស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គម ព្រមទាំងធានាសមភាពយេនឌ័រ (គុយបា)។

១៣៩.២១៨ បន្តពង្រឹងលិខិតបទដ្ឋានគតិយុត្តនិងគោលនយោបាយសាធារណៈស្តីពី សមភាពយេនឌ័រ និងការប្រយុទ្ធប្រឆាំងនឹងការរើសអើងលើស្ត្រី ព្រមទាំងការចូលរួម និងភាពតំណាងរបស់ស្ត្រីនៅក្នុងតួនាទីដឹកនាំ (បូលីវី)។

១៣៩.២១៩ បង្កើនកិច្ចខិតខំប្រឹងប្រែងទ្វេដង ដើម្បីលុបបំបាត់ការរើសអើងលើស្ត្រីនៅកម្រិតច្បាប់ និងបញ្ចប់ការអនុវត្តប្រកបដោយគ្រោះថ្នាក់ និងផ្នត់គំនិតរើសអើង ដែលស្ត្រីកម្ពុជាជាជនរងគ្រោះនៃការអនុវត្តទាំងនេះ (អ៊ុយរ៉ូហ្គាយ)។

១៣៩.២២០ ពិចារណាពង្រឹងក្របខណ្ឌច្បាប់ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ (បារ៉ែន)។

១៣៩.២២១ បង្កើនកិច្ចខិតខំប្រឹងប្រែង ក្នុងការដោះស្រាយបញ្ហាការរើសអើង និងអំពើហិង្សាផ្អែកលើយេនឌ័រ រួមទាំងអំពើហិង្សាក្នុងគ្រួសារ លើស្ត្រី និងកុមារី (ម៉ុងហ្គោលី)។

១៣៩.២២២ ពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីប្រយុទ្ធប្រឆាំងអំពើហិង្សាផ្អែកលើយេនឌ័រ រួមទាំងអំពើហិង្សាក្នុងគ្រួសារ (ស៊ីប)។

១៣៩.២២៣ បង្កើនកិច្ចខិតខំប្រឹងប្រែងទ្វេដង ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី និងកុមារី (នេប៉ាល់)។

១៣៩.២២៤ បន្តកិច្ចខិតខំប្រឹងប្រែងដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី និងលើកកម្ពស់សិទ្ធិ និងស្ថានភាពរបស់ស្ត្រី តាមរយៈការអនុវត្តគោលនយោបាយសមភាពយេនឌ័រប្រកបដោយប្រសិទ្ធភាព ក្នុងគ្រប់វិស័យ (អាល់ហ្សេរី)។

១៣៩.២២៥ បង្កើនកិច្ចខិតខំប្រឹងប្រែងទ្វេដង ក្នុងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ប្រកបដោយប្រសិទ្ធភាព (ប៉ាគីស្ថាន)។

១៣៩.២២៦ ពង្រឹងច្បាប់ជាធរមានជាមួយនឹងវិធានការនានា ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី (ក្រូអាស៊ី)។

១៣៩.២២៧ ខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយអំពើហិង្សាផ្អែកលើយេនឌ័រគ្រប់ទម្រង់ រួមទាំងការចាត់វិធានការអនុវត្តជាក់ស្តែង ដើម្បីកាត់បន្ថយការរំលោភបំពានក្នុងគ្រួសារ (ឥណ្ឌា)។

១៣៩.២២៨ ធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងធ្វើឱ្យច្បាប់នេះអនុលោមតាមក្រមព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី ដោយធានាថា ច្បាប់នេះកំណត់ ហាមឃាត់ និងកំណត់ជាបទល្មើសរាល់ទម្រង់នៃអំពើហិង្សាផ្អែកលើយេនឌ័រ (អ៊ីស្លង់)។

១៣៩.២២៩ កែទម្រង់ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដើម្បីអនុវត្តវិធានការនានាដែលធានាកិច្ចការពារស្ត្រីប្រកបដោយប្រសិទ្ធភាព និងការរៀបចំក្របខណ្ឌលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់ដែលធានាបង្កើនកូតាចូលរួមរបស់ស្ត្រី ក្នុងស្ថាប័នសាធារណៈ (អេស្ប៉ាញ)។

១៣៩.២៣០ ជំរុញវិសោធនកម្មច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដើម្បីឱ្យជនរងគ្រោះមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានយុត្តិធម៌ (កូឡុំប៊ី)។

១៣៩.២៣១ ពង្រឹងកិច្ចការពារសិទ្ធិស្ត្រី ជាពិសេស តាមរយៈកំណែទម្រង់ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដើម្បីឱ្យច្បាប់នេះអនុលោមនឹងអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិមនុស្ស (ទ្បេសូតូ)។

១៣៩.២៣២ ធានាថាមានការស៊ើបអង្កេតពេញលេញ លើសំណុំរឿងពាក់ព័ន្ធនឹងការរើសអើង និងអំពើហិង្សាផ្អែកលើយេនឌ័រលើស្ត្រី និងកុមារី ចំណែកជនល្មើសត្រូវបានផ្តន្ទាទោស និងដាក់ទណ្ឌកម្មសមស្របនឹងកម្រិតបទល្មើស ហើយជនរងគ្រោះទទួលបានសំណង (លិចតិនស្តាញ)។

១៣៩.២៣៣ ធានាថាមានការស៊ើបអង្កេតពេញលេញ លើសំណុំរឿងពាក់ព័ន្ធនឹងការរើសអើង និងអំពើហិង្សាផ្អែកលើយេនឌ័រលើស្ត្រី ចំណែកជនល្មើសត្រូវបានផ្តន្ទាទោស និងដាក់ទណ្ឌកម្មសមស្របនឹងកម្រិតបទល្មើស ហើយជនរងគ្រោះទទួលបានសំណង (អ៊ុយក្រែន)។

១៣៩.២៣៤ រៀបចំធ្វើវិសោធនកម្មច្បាប់ ដើម្បីពង្រឹងកិច្ចការពារជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាផ្អែកលើយេនឌ័របន្ថែមទៀត និងធានាថាមានការស៊ើបអង្កេតពេញលេញលើសំណុំរឿងពាក់ព័ន្ធនឹងការរើសអើង និងអំពើហិង្សាផ្អែកលើយេនឌ័រលើស្ត្រី រួមទាំង អំពើហិង្សាក្នុងគ្រួសារ ចំណែកជនល្មើសត្រូវបានផ្តន្ទាទោស និងដាក់ទណ្ឌកម្មសមស្របនឹងកម្រិតបទល្មើស ហើយជនរងគ្រោះទទួលបានសំណង (ប៊ុលហ្គារី)។

១៣៩.២៣៥ ធានាថាមានការស៊ើបអង្កេតពេញលេញ លើសំណុំរឿងពាក់ព័ន្ធនឹងការរើសអើង និងអំពើហិង្សាលើស្ត្រី ចំណែកជនល្មើសត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ហើយជនរងគ្រោះទទួលបានកិច្ចការពារ និងសំណង (ស្លូវេនី)។

១៣៩.២៣៦ បន្តចាត់វិធានការ និងអនុវត្តសកម្មភាព ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ ផ្លាស់ប្តូរឥរិយាបថសង្គម កៀរគរការចូលរួម និងលើក

ទឹកចិត្តការផ្តល់ភាពអង់អាចដល់ស្ត្រី និងការចូលរួមរបស់បុរសក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ (ស៊ែប៊ី)។

១៣៩.២៣៧ ពន្លឿនដំណើរការអនុម័តច្បាប់ ស្តីពី កិច្ចការពារកុមារគ្រប់ជ្រុងជ្រោយ ដែលអនុលោមនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ (ម៉ុងហ្គោលី)។

១៣៩.២៣៨ ចាត់វិធានការបន្ថែមទៀត ឆ្ពោះទៅរកការអនុម័តច្បាប់ ស្តីពី កិច្ចការពារកុមារគ្រប់ជ្រុងជ្រោយ ដែលផ្អែកលើគោលការណ៍ និងបទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (ហ្សកហ្ស៊ី)។

១៣៩.២៣៩ អនុម័តច្បាប់គ្រប់ជ្រុងជ្រោយមួយ ដែលបញ្ចូលរាល់គោលការណ៍ និងបទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (ម៉ុងតេណេហ្គ្រោ)។

១៣៩.២៤០ កែសម្រួលច្បាប់ជាតិ ដើម្បីឱ្យច្បាប់នោះអនុលោមនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដោយយកចិត្តទុកដាក់ជាពិសេស ចំពោះបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ និងប្រព័ន្ធយុត្តិធម៌អនីតិជន (អ៊ុយរូហ្គាយ)។

១៣៩.២៤១ ពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការពិនិត្យតាមដាន និងស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព លើសំណុំរឿងទាំងអស់ពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទលើកុមារ ធានាថាជនល្មើសត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងផ្តល់សេវាគាំទ្រគ្រប់គ្រាន់ដល់កុមាររងគ្រោះ (លីទុយអានី)។

១៣៩.២៤២ ពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការបង្ការ និងការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ និងហានិភ័យពាក់ព័ន្ធផ្សេងទៀត (ថៃ)។

១៣៩.២៤៣ បន្តពង្រឹងប្រព័ន្ធការពារសិទ្ធិកុមារ រួមទាំងក្នុងក្របខណ្ឌនៃផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (២០១៦-២០២៥) និងឯកសារកម្មវិធីថ្នាក់ជាតិផ្សេងទៀត (បេឡារុស)។

១៣៩.២៤៤ បន្តពង្រឹងកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់ និងការពារសិទ្ធិជនមានពិការភាព តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពប្រកបដោយប្រសិទ្ធភាព (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ)។

១៣៩.២៤៥ បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់បរិយាបន្ន និងគាំទ្រជនមានពិការភាព (អាស៊ែបៃហ្សង់)។

១៣៩.២៤៦ បន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រឹងគុណភាពជីវិតរបស់ជនមានពិការភាព និងការទទួលបានប្រព័ន្ធថែទាំសុខភាពដែលមានគុណភាព (គុយបា)
។

១៣៩.២៤៧ ពិចារណាអនុម័តច្បាប់ជាក់លាក់ ស្តីពី កិច្ចការពារសិទ្ធិជនមានពិការភាព ដោយអនុលោមនឹងអនុសញ្ញាស្តីពីសិទ្ធិមានពិការភាព (លីទុយអានី) ។

១៣៩.២៤៨ ធានាថា ច្បាប់ទាំងអស់ពាក់ព័ន្ធនឹងកិច្ចការពារសិទ្ធិជនមានពិការភាព គឺអនុលោមទៅតាមអនុសញ្ញាស្តីពីសិទ្ធិជនមានពិការភាព (ព័រទុយហ្គាល់) ។

១៣៩.២៤៩ អនុម័តច្បាប់ ស្តីពី កិច្ចការពារសិទ្ធិជនមានពិការភាព និងពង្រឹងសេវាការពារដើម្បីទប់ស្កាត់ការរំលោភបំពាន និងធានាសុវត្ថិភាព និងសុខុមាលភាពរបស់កុមារទាំងអស់ ជាពិសេស កុមារមានពិការភាព (ហ្គំប៊ី)។

១៣៩.២៥០ បន្តវិធានការនានា ដើម្បីធានាសិទ្ធិរបស់ជនមានពិការភាព និងប្រភេទប្រជាពលរដ្ឋដែលងាយរងគ្រោះផ្សេងទៀត (បេឡារុស)

១៣៩.២៥១ បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តយុទ្ធសាស្រ្តជាតិ ស្តីពី ពិការភាព និងពិចារណាអនុម័តច្បាប់ ស្តីពី សិទ្ធិជនមានពិការភាព (ប៊ូតង់)។

១៣៩.២៥២ ពិចារណាអនុម័តក្របខណ្ឌច្បាប់សមស្របមួយ ដើម្បីទទួលស្គាល់ និងការពារសិទ្ធិជនជាតិដើមភាគតិច និងជនជាតិភាគតិចពាក់ព័ន្ធនឹងដីធ្លី និងធនធាន (អ៊ីតាលី)។

១៣៩.២៥៣ ពង្រឹងកិច្ចការពារសិទ្ធិជនជាតិដើមភាគតិច (លីបង់)។

១៣៩.២៥៤ បន្តពង្រឹងក្របខណ្ឌលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសាធារណៈ ដើម្បីធានាសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រជាពលរដ្ឋដោយផ្តោតលើជនជាតិដើមភាគតិច (បូលីវី)។

១៣៩.២៥៥ បង្កើតកម្មវិធីដើម្បីថែរក្សាការអនុវត្តជាទម្លាប់ ប្រវត្តិសាស្រ្ត ភាសា និងវប្បធម៌ប្រកបដោយចីរភាពរបស់ជនជាតិដើមភាគតិច (ប៉ាណាម៉ា)។

១៣៩.២៥៦ លើកស្ទួយកម្រិតជីវភាពរបស់ជនជាតិដើមភាគតិច តាមរយៈការទទួលស្គាល់សិទ្ធិដីធ្លី កម្មវិធីអភិវឌ្ឍ និងការអប់រំពហុភាសា (វ៉ានូទូ)។

១៣៩.២៥៧ ចាត់វិធានការនានា ដើម្បីការពារសិទ្ធិរបស់ជនជាតិដើម ទាក់ទងនឹងការអនុវត្តផ្តល់ដីសម្បទានសេដ្ឋកិច្ច និងគម្រោងសាងសង់ទំនប់វារីអគ្គិសនី រួមទាំង តាមរយៈការពិគ្រោះយោបល់ជាមុនប្រកបដោយអត្ថន័យ គ្រោងការណ៍ដោះស្រាយច្បាស់លាស់ និងសំណងគ្រប់គ្រាន់ (ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង)។

១៣៩.២៥៨ បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងការរើសអើងលើជនជាតិដើមភាគតិច និងជនជាតិភាគតិច (ម៉ាឡាវី)។

១៣៩.២៥៩ បន្តកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកសិទ្ធិស្មើគ្នាសម្រាប់ LGBT+ (បារាំង)។

១៣៩.២៦០ ធានាបរិយាបន្ន និងកិច្ចការពារប្រកបដោយប្រសិទ្ធភាពសម្រាប់ LGBTIQ នៅក្នុងច្បាប់ និងគោលនយោបាយពាក់ព័ន្ធ ដើម្បីប្រយុទ្ធប្រឆាំងការរើសអើង និងអំពើហិង្សាផ្អែកលើយេនឌ័រ ទាំងនៅសាលារៀន វិស័យការងារ វិស័យថែទាំសុខភាព និងតាមកន្លែងសាធារណៈ (ស៊ុយអែត)។

១៣៩.២៦១ ធានាបរិយាបន្ន និងកិច្ចការពារប្រកបដោយប្រសិទ្ធភាពចំពោះអ្នកដែលមាន និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងលក្ខណៈភេទ (SOGIESC) ចម្រុះ នៅក្នុងច្បាប់ និងគោលនយោបាយពាក់ព័ន្ធ (អ៊ីស្លង់)។

១៣៩.២៦២ អនុម័តវិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីប្រយុទ្ធប្រឆាំង និងដាក់ទណ្ឌកម្មចំពោះការរើសអើង និងអំពើហិង្សាផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ (អ៊ុយរូហ្គាយ)។

១៣៩.២៦៣ បន្តវឌ្ឍនភាព ឆ្ពោះទៅការទទួលស្គាល់ស្របច្បាប់ចំពោះអាពាហ៍ពិពាហ៍ភេទដូចគ្នា (កាណាដា)។

១៣៩.២៦៤ បន្តវឌ្ឍនភាពជាវិជ្ជមាន ឆ្ពោះទៅរកសមភាពពេញលេញសម្រាប់ LGBTQIA+ រួមទាំងការទទួលស្គាល់ស្របច្បាប់ចំពោះអាពាហ៍ពិពាហ៍ភេទដូចគ្នា (អូស្ត្រាលី)។

១៣៩.២៦៥ បន្តវឌ្ឍនភាពឆ្ពោះទៅការអនុម័តវិសោធនកម្មច្បាប់ ក្នុងការទទួលស្គាល់សមភាពអាពាហ៍ពិពាហ៍ស្របច្បាប់ចំពោះគូស្វាមីភរិយាភេទដូចគ្នា ដើម្បីធានាសមភាព និងបរិយាបន្នសង្គមពេញលេញ សម្រាប់ LGBTQI+ (ព្រះរាជាណាចក្រហូឡង់)។

១៣៩.២៦៦ អនុម័តវិសោធនកម្មច្បាប់ ក្នុងការទទួលស្គាល់អាពាហ៍ពិពាហ៍ភេទដូចគ្នា ដើម្បីឱ្យមានសមភាពចំពោះមុខច្បាប់ ដែលនឹងសម្រេចបានការមិនរើសអើង សមភាព និងបរិយាបន្នសង្គមពេញលេញ សម្រាប់ LGBTIQ នៅកម្ពុជា (អាល្លឺម៉ង់)។

១៣៩.២៦៧ រៀបចំឱ្យមានច្បាប់ និងធ្វើវិសោធនកម្មច្បាប់ជាធរមាន ដើម្បីទទួលស្គាល់សមភាពអាពាហ៍ពិពាហ៍ សម្រាប់គូស្វាមីភរិយាភេទដូចគ្នា (ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង)។

១៣៩.២៦៨ ទទួលស្គាល់អាពាហ៍ពិពាហ៍ភេទដូចគ្នា ឱ្យមានសមភាពចំពោះមុខច្បាប់ (អ៊ីស្លង់)។

១៣៩.២៦៩ ពន្លឿនការរៀបចំក្របខណ្ឌច្បាប់ ដែលទទួលស្គាល់ស្របច្បាប់ចំពោះអត្តសញ្ញាណយេនឌ័រកំណត់ដោយសាមីខ្លួន ព្រមទាំងអាពាហ៍ពិពាហ៍ស្មើភាពគ្នារវាងអ្នកមានភេទដូចគ្នា (ម៉ិកស៊ិក)។

១៣៩.២៧០ អនុម័ត និងអនុវត្តនីតិវិធីរដ្ឋបាលប្រកបដោយតម្លាភាព សម្រាប់ការទទួលស្គាល់ផ្លូវច្បាប់ចំពោះយេនឌ័រកំណត់ដោយសាមីខ្លួន (អ៊ីស្លង់)។

១៣៩.២៧១ ពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីការពារសិទ្ធិពលករចំណាកស្រុកនៅក្នុងវិស័យសិទ្ធិការងារ (ឥណ្ឌូនេស៊ី)។

១៣៩.២៧២ ធានាថា ជនភៀសខ្លួនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានសញ្ជាតិកម្ពុជា ឬទម្រង់ផ្សេងទៀតនៃឋានៈអចិន្ត្រៃយ៍ក្នុងប្រទេស ដែលពួកគេមានសិទ្ធិទទួល ដូចមានចែងក្នុងច្បាប់ (ប៉ារ៉ាហ្គាយ)។

១៣៩.២៧៣ ធានាថា ជនភៀសខ្លួនអាចទទួលបានវិធីសាស្ត្រនានាប្រកបដោយប្រសិទ្ធភាពដើម្បីទទួលបានសញ្ជាតិកម្ពុជា ឬទម្រង់ផ្សេងទៀតនៃឋានៈអចិន្ត្រៃយ៍ក្នុងប្រទេស ដែលពួកគេមានសិទ្ធិទទួល ដូចមានចែងក្នុងច្បាប់ (សៀរ៉ាឡេអូន)។

១៣៩.២៧៤ ពង្រឹងកិច្ចខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់ភាពគ្មានរដ្ឋ តាមរយៈការធានាការចុះបញ្ជីកំណើតរបស់បុគ្គលទាំងអស់ ដែលកើតនៅកម្ពុជា និងផ្តល់វិធីសាស្ត្រផ្នែកច្បាប់ក្នុងការទទួលបានសញ្ជាតិ ឬទម្រង់ផ្សេងទៀតនៃឋានៈអចិន្ត្រៃយ៍សម្រាប់ជនភៀសខ្លួន (ហ្គំប៊ី)។

១៣៩.២៧៥ ចាត់វិធានការអនុវត្តជាក់ស្តែង ដើម្បីអនុវត្តច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ដែលទើបអនុម័តថ្មីៗ ឱ្យបានពេញលេញ ដើម្បីធានាលទ្ធភាពជាសកលក្នុងការទទួលបានឯកសារចាំបាច់ និងឯកសារអត្តសញ្ញាណ (សៀរ៉ាឡេអូន)។

១៤០. សេចក្តីសន្និដ្ឋាន និង/ឬអនុសាសន៍ទាំងអស់ដែលមាន ក្នុងរបាយការណ៍បច្ចុប្បន្នឆ្លុះបញ្ចាំងគោលជំហររបស់រដ្ឋដែលបានដាក់បញ្ជូន និង/ឬរដ្ឋ ដែលកំពុងស្ថិតក្រោមការពិនិត្យឡើងវិញនេះ។ សេចក្តីសន្និដ្ឋាន និង/ឬអនុសាសន៍ទាំងនេះមិនគួរត្រូវបានបកស្រាយថា ត្រូវបានអនុម័តពីក្រុមការងារទាំងមូលឡើយ។

# ឧបសម្ព័ន្ធ

## សមាសភាពនៃគណៈប្រតិភូ

គណៈប្រតិភូកម្ពុជា ក្រោមការដឹកនាំរបស់ ឯកឧត្តម កែវ សុទ្ធិ អនុប្រធាន គណៈកម្មាធិការ សិទ្ធិមនុស្សកម្ពុជា និង មានសមាជិកដូចខាងក្រោម៖

- ឯកឧត្តម អ៊ិន តារា ឯកអគ្គរាជទូត ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានានៅទីក្រុងហ្សឺណែវ
- លោកជំទាវ ឡុង សូនីតា អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- ឯកឧត្តម នាក់ សើគីរីន រដ្ឋលេខាធិការក្រសួងយុត្តិធម៌
- ឯកឧត្តម ឌី ខាំបូលី អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ ក្រសួងអប់រំ យុវជន និងកីឡា
- ឯកឧត្តម សោម ចំណាន រដ្ឋលេខាធិការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- លោកជំទាវ ញាណ សុចិត្រា អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី
- ឯកឧត្តម ប៉ាង វ៉ាស៊ី អនុប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ
- លោក សុក ឬទ្ធិចាក់ ជំនួយការឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រះរាជាណាចក្រកម្ពុជា
- លោក នួន រិទ្ធីវឌ្ឍន៍ ទីប្រឹក្សា នៃស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានានៅទីក្រុងហ្សឺណែវ
- លោក កង សុភ័ក្រ្តាដារ៉ាវិទូ លេខាធិការទី២ នៃស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានានៅទីក្រុងហ្សឺណែវ។